■ លោក ហាក់ តា ច្នៃសំបកកំប៉ុងជាវត្ថុមានតម្លៃ <ទំព័រ៖ ៧



■ ត្រីស្តបរិស័ទក្នុងភូមិភាគបាត់ដំបងរិះគិតពី «Synodal Church» <ទំព័រ៖ ១៣

■ «ព្រះសហគមន៍គឺជាគ្រួសាររបស់ខ្ញុំ» <ទំព័រ៖ ១៩




កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១៣

# អ្នកនាំសារ
# the messenger

ខែ ធ្នូ | ឆ្នាំ ២០២៣ | លេខទី ១៦១

www.catholiccambodia.org/km/ | www.facebook.com/RVAKHMER/ | https://khmer.rvasia.org/ | December, 2023 | #161




## «យុទ្ធសាស្រ្តចក្រាវិស័យបរិស្ថាន» ឆ្នាំ២០២៣-២០២៨ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាដាក់ឱ្យអនុវត្ត

រឿងពេញទំព័រទី ១០-១១

## តើអ្នកដឹងទេ ប្លាស្ទិកប្រើពេលប៉ុន្មានពាន់ឆ្នាំដើម្បីរលាយខ្លួន?

រឿងពេញទំព័រទី ៣

## និស្សិតប្លាស្ទិក៖ «គោលដៅធំគឺផ្លាស់ប្តូរឥរិយាបទបោលសំរាមរបស់ពលរដ្ឋ»

រឿងពេញទំព័រទី ៤

## សុភមង្គលគ្រួសារមិនពឹងតែលើទ្រព្យសម្បត្តិ

រឿងពេញទំព័រទី ១៧



# ការអំពាវនាវឱ្យអភិរក្សថែរក្សា បរិស្ថានកម្ពុជា

នៅចំកណ្តាលអាស៊ីអាគ្នេយ៍ គឺប្រទេសកម្ពុជា ដែលជាប្រទេសមានបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែប និងទេសភាពដ៏អស្ចារ្យ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលប្រទេសរីកចម្រើន បរិស្ថានប្រឈមមុខនឹងការគំរាមកំហែងដ៏គួរឱ្យព្រួយបារម្ភ ជាចម្បងពីការប្រើប្រាស់ថង់ប្លាស្ទិកដ៏ច្រើនសន្ធឹកសន្ធាប់ និងការអនុវត្តការចោលកាកសំណល់គ្មានសណ្តាប់ធ្នាប់។

ជាការចាំបាច់ដែលយើងជាអ្នកថែរក្សាទឹកដីដ៏ស្រស់ស្អាតនេះ ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីការពារ និងអភិរក្សអច្ឆរិយៈធម្មជាតិរបស់កម្ពុជាយើង។

ការប្រើប្រាស់ថង់ប្លាស្ទិកដ៏ច្រើននិងសម្បូរបែប កំពុងរួមចំណែកដល់ការរិចរិលបរិស្ថានក្នុងអត្រាគួរឱ្យព្រួយបារម្ភមួយ។ ទន្លេ ព្រៃឈើ និងទីធ្លាទីក្រុងរបស់យើង ទទួលរងនូវការឈ្លានពានពីប្លាស្ទិកនេះ។ ដើម្បីទប់ជំនោរនេះ សូមឲ្យយើងរួមគ្នាប្តេជ្ញាកាត់បន្ថយការពឹងផ្អែករបស់យើងលើថង់ប្លាស្ទីក។ ការទទួលយកជម្រើសដែលមិនប៉ះពាល់ដល់បរិស្ថានដូចជា ថង់ដែលអាចប្រើឡើងវិញបាន អាចកាត់បន្ថយផលប៉ះពាល់បរិស្ថានយ៉ាងច្រើនអនេក និងការពារប្រព័ន្ធអេកូឡូស៊ីចម្រុះដែលធ្វើឱ្យប្រទេសកម្ពុជាអាចរួចផុតពីការបំពុល។

លើសពីនេះទៀត ការចោលសំរាមឱ្យបានត្រឹមត្រូវគឺមានសារៈសំខាន់ក្នុងការរក្សាបាននូវសុចរិតភាពនៃបរិស្ថានរបស់យើង។ ការបង្កើត និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសំណល់ដែលអាចជឿទុកចិត្តបាន ដោយធានាថាសម្ភារដែលបានបោះចោលរបស់យើងមិនធ្វើឱ្យប៉ះពាល់ដល់ដី និងទឹករបស់យើងឡើយ។ ពួកយើងទាំងអស់គ្នាសូមចូលរួម បែងចែកកាកសំណល់របស់យើងដោយការទទួលខុសត្រូវ កែច្នៃឡើងវិញនូវអ្វីដែលយើងអាចធ្វើបាន និងបោះចោលសំណល់នៅកន្លែងដែលបានកំណត់។

ដូចដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ មានបន្ទូលដោយប្រាជ្ញាថា ៖ «ផែនដី ដែលជាផ្ទះរបស់យើង កំពុងតែចាប់ផ្តើមមើលទៅដូចជាគំនរសំរាមដ៏សម្បើម»។ ពាក្យទាំងនេះបានបន្លឺឡើងយ៉ាងជ្រាលជ្រៅនៅក្នុងបរិបទនៃបញ្ហាប្រឈមផ្នែកបរិស្ថានរបស់កម្ពុជា។ សូមឱ្យយើងរិះគិតអំពីកិច្ចប្រឈមនេះ គឺឱ្យយើងធ្វើសកម្មភាព ដោយទទួលខុសត្រូវដើម្បីថែរក្សាផ្ទះរួមរបស់យើង។ តាមរយៈការផ្លាស់ប្តូរតិចតួចរបស់យើង តែវាមានឥទ្ធិពលនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង យើងអាចបង្កើតបរិយាកាសប្រកបដោយនិរន្តរភាពសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត។ រួមគ្នាជាធ្លុងមួយ ថែរក្សាសម្រស់ធម្មជាតិរបស់កម្ពុជា ដោយប្រកាន់យកនូវបញ្ញាទទួលខុសត្រូវ ធ្វើទង្វើតូចតាចដោយចិត្តស្រឡាញ់ចំពោះបរិស្ថាន និងរួមចំណែកគ្រប់កិច្ចការការពារបរិស្ថាននៅជុំវិញខ្លួនរបស់យើងផ្ទាល់៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

**ចាងហ្វាង : លោក លី សុវណ្ណា**
សេចក្តីប្រកាសលេខ៖ លេខចុះបញ្ជី២០២២៖ ១២៧៩|២២ឆត.ប្រ
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
**Contact: (855) 17 726 060**
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# ដឹងទេ ប្លាស្ទិកប្រើពេលប៉ុន្មានពាន់ឆ្នាំដើម្បីរលាយខ្លួន?

*អត្ថបទ៖ អមរិន្ទ ដានុត*

ថង់ប្លាស្ទិកសំដៅដល់វត្ថុផលិតពីប្លាស្ទិកទន់ អាចបត់បែនបានស្រួល និងមិនងាយស្រួល និងមិនងាយពុកផុយ ប្រើសម្រាប់ផ្ទុក វេចខ្ចប់ទំនិញ និងសម្ភារផ្សេងៗ។ ថង់ប្លាស្ទិកងាយស្រួលសម្រាប់ការវេចខ្ចប់ ប៉ុន្តែភាគច្រើនប្រើវាតែម្តងរួចក៏បោះចោល។

យោងតាមការសិក្សាស្រាវជ្រាវដែលបង្ហាញដោយក្រសួងបរិស្ថានបានឱ្យដឹងថា សំណល់ប្លាស្ទិកប្រើរយៈពេលជាច្រើនរយឆ្នាំ ខ្លះជាង ១០០០ឆ្នាំដើម្បីរលាយ។ សារធាតុគីមីនៃប្លាស្ទិកត្រូវបានបំបែកជាកម្ទេចជាតុល្អិតៗដែលនៅលាយឡំជាមួយទឹក។ កម្ទេចល្អិតៗនៃប្លាស្ទិកអាចមាននៅក្នុងសារពាង្គកាយមនុស្សយើងតាមរយៈការបរិភោគទឹក ឬតាមរយៈការបរិភោគត្រីដែលមានផ្ទុកកម្ទេចល្អិតៗទាំងនោះ។

ដោយសង្កេតឃើញពីផលប៉ះពាល់ និងការប្រើប្រាស់ថង់ប្លាស្ទិករបស់ប្រជាពលរដ្ឋកម្ពុជានៅតែបន្តមានច្រើន ក្រសួងបរិស្ថាន បានបង្កើតយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» ដែលអនុវត្តចាប់ពីថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២៣។




រដ្ឋមន្ត្រីក្រសួងបរិស្ថាន លោក អ៊ាង សុផល្លែត ដែលជាអ្នកផ្តួចផ្តើមគំនិត និងយុទ្ធនាការនេះ បានលើកឡើងថា យុទ្ធនាការនេះធ្វើឡើងដើម្បីលើកកម្ពស់ សុខុមាលភាពប្រជាពលរដ្ឋ សោភ័ណភាពទីក្រុង និងមូលដ្ឋាន ឱ្យបានប្រសើរឡើង បន្ថែមទៀត ព្រមទាំងលើកស្ទួយសេដ្ឋកិច្ចជាតិផងដែរ តាមរយៈការលើកកម្ពស់ការប្រើ ប្រាស់ផលិតផលក្នុងស្រុក ជំនួសថង់ប្លាស្ទិក។

លោក អ៊ាង សុផល្លែត បានមានប្រសាសន៍ថា ៖ «ការចូលរួមអនុវត្តយុទ្ធនាការនាថ្ងៃនេះ គឺជាសក្ខីភាពនៃការគាំទ្រ និងការជំរុញអនុវត្ត ចលនាកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ដើម្បីបរិស្ថានកម្ពុជា ដែលជាផ្ទះរបស់យើងស្រស់ស្អាតបំព្រង»។

យុទ្ធនាការនេះ ចាប់ផ្តើមដំបូងគឺធ្វើនៅតាមសាលារៀន បន្ទាប់មកតាមរោងចក្រសហគ្រាស និងសហគមន៍ផ្សេងៗ ដែលមកដល់ពេលនេះ ចលនាសិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ នៅតាមសាលារៀន មានជាងពាលាននាក់ហើយ នៅទូទាំងប្រទេស រួមនឹងកម្មករ កម្មការិនី រាប់ម៉ឺននាក់មកពីរោងចក្រសហគ្រាសនានា ប្រជាពលរដ្ឋ រួមនឹងព្រះសង្ឃតាមបណ្តាវត្តអារាម ក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តផងដែរ។ កុមារី ម៉ី ហៀង អាយុ១១ឆ្នាំ រៀនថ្នាក់ទី៥ បានប្រាប់ឱ្យដឹងថា សម្រាម ជាពិសេសប្លាស្ទិកធ្វើឱ្យប៉ះពាល់ខ្លាំងមិនថាតែសម្រាប់មនុស្សទេ តែគឺប៉ះពាល់ដល់បរិស្ថាន សត្វ មិនថាលើគោក ឬក្នុងទឹកឡើយ។

កុមារីរូបនេះបាននិយាយថា ៖ «ខ្ញុំបានចូលរួមយុទ្ធនាការសម្អាតបរិស្ថានជាមួយមិត្តភក្តិ លោកគ្រូអ្នកគ្រូដោយប្រមូលសម្រាមប្លាស្ទិកនៅក្នុងបរិវេណសាលា សហគមន៍ និងក្នុងទឹក ដើម្បីឱ្យប្រជាពលរដ្ឋ អ៊ំពូមីងយាយតា និងមិត្តភក្តិទាំងអស់យល់ដឹងពីផលប៉ះពាល់របស់ប្លាស្ទិក និងរួមគ្នាឈប់ប្រើ ឬកាត់បន្ថយការប្រើប្លាស្ទិក»។

កុមារី ម៉ី ហៀង បាននិយាយទៀតថា នាងតែងតែប្រាប់អ្នកភូមិរបស់នាងថា ប្រសិនបើទៅផ្សារទិញម្ហូប ឬបន្លែ ត្រូវយកកន្ត្រកទៅតាមជាមួយ ឬបើទិញបាយត្រូវយកចាន ឬរបស់អ្វីមួយទៅដាក់ដើម្បីកាត់បន្ថយប្រើប្លាស្ទិកទៀត។

«នៅពេលដែលខ្ញុំសម្រេចចិត្តហាងរបស់ខ្ញុំមិនប្រើប្លាស្ទិក យ៉ាងហោចណាស់អ្នកដែលឃើញដូចនេះ គេនឹងសរសើរ ឬលើកឡើងថាហាងនេះមិនប្រើប្លាស្ទិកតែម្តង គេអាចធ្វើបាន»។ នេះជាការលើកឡើងរបស់ម្ចាស់ភោជនីយដ្ឋានមួយដែលដែលមិនប្រើប្រាស់ប្លាស្ទិកសម្រាប់អាជីវកម្មរបស់នាង គឺអ្នកនាង ស្រ៊ុន សុខលីម ម្ចាស់ភោជនីយដ្ឋាន Eleven One Kitchen។

អ្នកនាងបានបន្តថា អ្វីដែលជំរុញឱ្យអ្នកនាងអាចធ្វើបានរហូតមកដល់សព្វថ្ងៃនេះបានគឺដោយសារតែអ្នកនាងពីផលប៉ះពាល់នៃប្លាស្ទិកច្រើន ដោយមើលនៅតាមផ្លូវ តាមសាធារណៈនានាសម្បូរទៅដោយប្លាស្ទិកគ្រប់ទីកន្លែង។

អ្នកនាង ស្រ៊ុន សុខលីម ថា ៖ «ការសម្រេចចិត្ត ការចូលរួមរបស់អ្នកទិញ ឬ អ្នកប្រើប្រាស់ផ្ទាល់គឺពិតជាសំខាន់មែនទែន ដែលធ្វើឱ្យសង្គមយើងងាកមករកអ្វីដែលទាក់ទងនឹងការមិនប្រើប្រាស់ប្លាស្ទិកនេះ»។

សូមបញ្ជាក់ផងដែរថា គិតត្រឹមថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រសួងបរិស្ថាន បានចុះអនុស្សរណៈយោគយល់ជាមួយនឹងខេត្តចំនួន ១៣ ខេត្ត និងស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាល ចំនួន៥ស្ថាប័ន សម្រាប់អនុវត្តនូវយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»។

ខេត្តចំនួន១៣ នោះរួមមាន៖ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ ខេត្តក្រចេះ កណ្តាល ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី កំពត កែប ព្រះសីហនុ កោះកុង កំពង់ស្ពឺ និងខេត្តតាកែវ។ ចំណែកអង្គការ សមាគមរួមមាន៖ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) សមាគមកាយឫទ្ធីនារីកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា រួមនឹងកាកបាទក្រហមកម្ពុជា ផងដែរ៕

# ដូរពីអាហារ៦ប្រភេទមិនល្អ មកជាអាហារខ្មែរវិញ

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងអប់រំ យុវជន និងកីឡា មិនអនុញ្ញាតឱ្យមានការលក់ដូរអាហារចំនួន៦ប្រភេទនៅក្នុងសាលារៀនឡើយដែលអាហារទាំងនោះរួមមាន៖ ចំណីអាហារគ្រប់ប្រភេទ ដែលហួសកំណត់កាលបរិច្ឆេទប្រើប្រាស់ គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់ ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែម កាហ្វេ ការ៉េម និងទឹកសេរ៉ូគ្រប់ប្រភេទ ស្ករសូកូឡា ស្ករគ្រាប់ និងស្ករកៅស៊ូគ្រប់ប្រភេទ និងចាហួយគ្រប់ប្រភេទ នំដូណាត់ និងនំផ្អែម។





ជំនួសឱ្យការលក់អាហារទាំង៦ប្រភេទនេះ ក្រសួងអប់រំ បានអនុញ្ញាត និងលើកទឹកចិត្តឱ្យគ្រប់សាលារដ្ឋទាំងអស់លក់នូវអាហារជាប្រភេទនំខ្មែរវិញ ដូចជា បង្អែម នំខ្មែរ ផ្លែឈើស្រស់ បបរ បាយ និងនំបញ្ចុកជាដើម។

កុមារី ឆាយ ម៉ូលីកា អាយុ១១ ឆ្នាំ រស់នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ បាននិយាយថា អ្នកគ្រូតែងតែប្រាប់សិស្សទាំងអស់ឱ្យញ៉ាំអាហារល្អមានសុខភាព មិនឱ្យញ៉ាំរបស់ផ្អែមពេក ឬប្រៃពេកទេ រួមនឹងនំកញ្ចប់ផងដែរដោយសារវាធ្វើឱ្យប៉ះពាល់ដល់សុខភាព។

កុមារីម៉ូលីកា បានថា ៖ «ធ្លាប់ឈឺពោះពេលញ៉ាំនំកញ្ចប់ហើយ ហើយខ្ញុំលែងញ៉ាំនំហ្នឹងទៀតហើយ។ អ្នកគ្រូប្រាប់ថា កុំញ៉ាំអាហារណាដែលមិនឆ្អិនល្អ និងទឹកដែលផ្អែមខ្លាំងពេក»។

យោងតាមរបាយការណ៍អាហារូបត្ថម្ភសកលឆ្នាំ២០២០ នៅកម្ពុជាមានកុមារអាយុចាប់ពី៥ដល់ ១៩ឆ្នាំចំនួនប្រមាណជាង ១ភាគ៨មានបញ្ហាឡើងទម្ងន់ និងជំងឺធាត់។



ចំនួន២ភាគបីនៃការស្លាប់នៅកម្ពុជាគឺបណ្តាលមកពីជំងឺមិនឆ្លង ហើយភាគច្រើនមានការជាប់ពាក់ព័ន្ធនឹងការបរិភោគចំណីអាហារ៕

# និស្សិតប្លាស្ទិកៈ

## « គោលដៅធំគឺផ្លាស់ប្តូរឥរិយាបទ ចោលសំរាមរបស់ពលរដ្ឋ »





*អត្ថបទ៖ អមរិទ្ធ ដានុត*

សំរាម និងសំណល់ប្លាស្ទិកកំពុងបំពុលប្រភពទឹកដែលបង្កហានិភ័យផ្នែកសុខភាពដល់អ្នកប្រើប្រាស់ទឹក និងអ្នករស់នៅក្នុងតំបន់ដែលរងការបំពុលជាពិសេសគឺកុមារ។

កាកសំណល់ប្លាស្ទិកកំពុងអណ្តែតរសាត់តាមទឹកពណ៌ខ្មៅកំពុងហូរ និងកកស្ទះនៅតាមមាត់លូក្នុងប្រឡាយសំខាន់ៗមួយចំនួន និងតាមទីសាធារណៈនានាក្នុងរាជធានីភ្នំពេញ រួមនឹងបណ្តាខេត្តមួយចំនួនដែលធ្វើឱ្យយុវជនមួយក្រុមដែលគេហៅថា «និស្សិតប្លាស្ទិក» មិននៅស្ងៀម រហូតមានការចុះប្រមូលសំរាមដោយមិនមានការខ្ពើមរអើម។

យុវជន ហែម សុភេម ឬត្រូវនិស្សិតក្នុងក្រុមប្រសិទ្ធនាមឱ្យថា «និស្សិតប្លាស្ទិក» គឺជាអ្នកដឹកនាំក្រុមយុវជន និស្សិតប្លាស្ទិក ចូលរួមធ្វើសកម្មភាពប្រមូលសំរាម និងផ្លាស្ទិកពីប្រឡាយទឹកនានា ដោយពួកគាត់ក៏បានចូលរួមលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ពីការប្រើប្រាស់ផ្លាស្ទិកបានតែម្តងទៅកាន់យុវជននិងសហគមន៍។

លោកបានបញ្ជាក់ថា ៖ «គោលបំណងធំរបស់ខ្ញុំគឺធ្វើយ៉ាងណាផ្លាស់ប្តូរឥរិយាបថនៃការចោលសំរាមរបស់ប្រជាពលរដ្ឋ នៅក្នុងការថែរក្សាសោភណភាពនៅតាមប្រឡាយ លូទឹកស្អុយនានា ហើយអ្វីជាសំខាន់ខ្ញុំព្យាយាមធ្វើជាយុវជនគំរូដល់យុវជនដទៃទៀតព្យាយាម ឬយកគំរូតាមខ្ញុំ ហើយយុវជននៅតាមបណ្តាខេត្តបានយកគំរូតាមខ្ញុំមែន ដោយបានសំអាតបរិស្ថានតាមតំបន់ដែលគាត់រស់នៅផងដែរ»។

ថ្មីៗនេះផងដែរ សកម្មភាពរបស់ «និស្សិតប្លាស្ទិក» បានទទួលនូវពានរង្វាន់ជើងឯកយុវជនអេកូអាស៊ានលើកទីពីរដោយ ក្រសួងបរិស្ថាន (The 2nd ASEAN Youth Eco-Champions AwardJunior) ដែលបានធ្វើឡើងនាប្រទេសឡាវ។

យុវជន ហែម សុភេម បានលើកឡើងថា ៖ «ខ្ញុំស្ទើរតែមិនជឿថាខ្ញុំត្រូវបានជ្រើសរើសជាយុវជនឆ្នើមនៃពានរង្វាន់ជើងឯកយុវជនអេកូអាស៊ានលើកទីពីរដោយ ក្រសួងបរិស្ថាន (The 2nd ASEAN Youth Eco-Champions Award Junior)។ ពានរង្វាន់នេះ គឺមិនមែនកើតចេញពីខ្ញុំម្នាក់ឯងនោះទេ តែវាកើតចេញពីយុវជនខ្មែរផ្សេងៗទៀតដែលបានចូលរួមចំណែកយ៉ាងសំខាន់ និងសកម្មក្នុងកិច្ចការពារបរិស្ថានជាមួយ និស្សិតប្លាស្ទិកនាពេលកន្លងមក»។






យុវជន ហែម សុភេម អាយុ ២២ ឆ្នាំ គឺជានិស្សិតកំពុងសិក្សានៅវិទ្យាស្ថានភាសាបរទេស [IFL] នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាអ្នកផ្តួចផ្តើមគំនិតដើរប្រមូលកាកសំណល់ប្លាស្ទិកដំបូងគេ រហូតមានការចូលរួមជាក្រុមពីយុវជនក្មេងៗជាច្រើនរូបទៀតដែលបានធ្វើសកម្មភាពជាង១ឆ្នាំហើយផងដែរ៕



> គោលបំណងធំរបស់ខ្ញុំគឺធ្វើយ៉ាងណាផ្លាស់ប្តូរឥរិយាបថនៃការចោលសំរាមរបស់ប្រជាពលរដ្ឋ នៅក្នុងការថែរក្សាសោភណភាពនៅតាមប្រឡាយ លូទឹកស្អុយនានា ហើយអ្វីជាសំខាន់ខ្ញុំព្យាយាមធ្វើជាយុវជនគំរូដល់យុវជនដទៃទៀតព្យាយាម ឬយកគំរូតាមខ្ញុំ ...





# ពិធី «រំលឹកគុណអង្គរ»

## ដើម្បីអរគុណដល់អ្នកកសាងនិងអ្នកថែរក្សាអង្គរ



*អត្ថបទ៖ អមរិទ្ធ ដានុត*

កម្ពុជា ជាពិសេសប្រជាពលរដ្ឋនៅក្នុងខេត្តសៀមរាប ដែលជាខេត្តទេសចរណ៍វប្បធម៌ដ៏ល្បីមួយមិនថាតែក្នុងប្រទេសប៉ុន្តែសម្រាប់ទូទាំងសកលលោកផងដែរ បានចូលរួមសប្បាយរីករាយ ប្រកបដោយមោទនភាពក្នុងការប្រារព្ធព្រឹត្តិការណ៍ «រំលឹកគុណអង្គរ» ប្រចាំឆ្នាំ២០២៣។

**តើអ្វីទៅជា «រំលឹកគុណអង្គរ»?**

ពិធីរំលឹកគុណអង្គរ ឬអរគុណអង្គរនេះ មិនសំដៅទៅលើប្រាសាទនោះទេ ប៉ុន្តែសំដៅលើស្នាដៃនៃការខិតខំប្រឹងប្រែងរបស់ព្រះមហាក្សត្រអង្គមុនៗដែលបានខិតខំប្រឹងប្រែងកសាង ក៏ដូចជាអ្នកសាងសង់ប្រាសាទនៅសម័យនោះ ហើយនឹងអ្នកដែលបានថែទាំប្រាសាទនិងជួលជុលឱ្យបានកាន់តែល្អទៀត។ ប្រសិនជាគ្មានការថែទាំទេ គឺមានន័យថា របស់ទាំងអស់នេះមិនអាចនៅរាប់ពាន់ឆ្នាំបានទេ ដែលនេះហើយជាបញ្ហាមួយដែលតែងតែធ្វើបុណ្យរំលឹកគុណទាំងអស់។

សម្រាប់ឆ្នាំ២០២៣នេះ ក្រសួងវប្បធម៌ និងអាជ្ញាធរជាតិអប្សរាបានរៀបចំពិធីរំលឹកគុណអង្គរ ដែលជាឆ្នាំទី៣ នៃការប្រារព្ធព្រឹត្តិការណ៍នេះ រាប់ចាប់ពីឆ្នាំ២០២១មក។

លោកស្រី ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌បានថ្លែងថា ព្រឹត្តិការណ៍រំលឹកគុណអង្គរធ្វើឡើងក្នុងគោលបំណងដើម្បីអបអរសាទរខួប៣១ឆ្នាំនៃការចុះរមណីយដ្ឋានអង្គរទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២-១៤ ខែធ្នូ ឆ្នាំ២០២៣។

លោកស្រីបានបញ្ជាក់ថា ៖ «អ្វីដែលពិសេសមួយទៀតនោះ គឺដើម្បីរំលឹកនឹកគុណដល់បុព្វការីជន ព្រះមហាក្សត្រជំនាន់មុនគ្រប់ព្រះអង្គ ដែលបានកសាងប្រាង្គប្រាសាទនានា បន្សល់ទុកនូវសម្បត្តិបេតិកភណ្ឌសិល្បៈ និងវប្បធម៌ជាច្រើនបម្រើនូវគុណប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជូនអ្នកជំនាន់នេះ និងទៅអនាគត»។

រដ្ឋមន្ត្រីក្រសួងវប្បធម៌ បានបញ្ជាក់ថា ពិធីនេះក៏ឧទ្ទិសផងដែរចំពោះបុព្វបុរសខ្មែរ ឥស្សរជនខ្មែរគ្រប់ជំនាន់ អ្នកជំនាញការជាតិ អន្តរជាតិ ដែលបានលះបង់កម្លាំងកាយកម្លាំងចិត្ត រហូតដល់អាយុជីវិតដើម្បីរក្សាការពារ និងអភិរក្សមរតកវប្បធម៌ជាតិ។

**មហាព្រឹត្តិការណ៍ទស្សនីយភាពសិល្បៈវប្បធម៌ដ៏អស្ចារ្យ "រាត្រីចងចាំ លើកទី៤" ឆ្នាំ២០២៣**

ដើម្បីអបអរសាទរនូវព្រឹត្តិការណ៍ «រំលឹកគុណអង្គរ» ឆ្នាំ២០២៣នេះដែរ ក៏មានការសម្តែងល្ខោន និងសិល្បៈទស្សនីយភាពនានាសម្រាប់ប្រជាពលរដ្ឋនៅគ្រប់ទិសទីនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣។

ការបង្ហាញជូននូវសម្បត្តិបេតិកភណ្ឌវប្បធម៌រូបីនិងអរូបី ព្រមទស្សនីយភាពសិល្បៈចម្រុះជាច្រើនទម្រង់។ មហាព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ក៏នឹងមានការចូលរួមសម្តែងពីសិល្បករ សិល្បការិនីទាំងក្នុងនិងក្រៅប្រព័ន្ធជាង៣០០នាក់។

លោក ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃកម្ពុជា បានលើកឡើងថា «រាត្រីចងចាំ» ដើម្បីចូលរួមអបអរសាទរខួប៣១ឆ្នាំនៃការដាក់បញ្ចូលរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌រូបីនៃពិភពលោករបស់អង្គការយូណេស្កូ និងដើម្បីអបអរសាទរពិធីបុណ្យរម្លឹកគុណអង្គរផងដែរ៕









# រកឃើញជំងឺអេដស៍ករណីថ្មីនៅតាមខេត្តនិងរាជធានីចំនួន៦









*អត្ថបទ៖ អរិយបុត្រ*

រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ និងខេត្តព្រះសីហនុ ត្រូវបានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍បានអះអាងថា គឺជាទីកន្លែងដែល គេរកឃើញករណីឆ្លងមេរោគអេសដ៏ថ្មីច្រើនបំផុត។

លោក អៀង មូលី ទេសរដ្ឋមន្ត្រី និងជាប្រធានបានលើកឡើងថា តាមលទ្ធផលបឋមនៃការសិក្សាប៉ាន់ប្រមាណបែបវិទ្យាសាស្ត្រ នៅឆ្នាំ២០២៣ ទាក់ទងនឹងចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិបានរកឃើញថា ទីតាំង៦ មានករណីឆ្លងមេរោគអេដស៍ថ្មីក្នុងចំណោមក្រុមប្រឈមខ្ពស់បំផុត។

លោកបានថ្លែងបញ្ជាក់ថា ៖ «រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ និងខេត្តព្រះសីហនុ ត្រូវគេរកឃើញថាមានអត្រាឆ្លងរហូតដល់៧២ ភាគរយ នៃការឆ្លងថ្មីនៅទូទាំងប្រទេស»។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍រូបនេះ បានបន្តថា ខេត្តតាកែវ និងខេត្តព្រះសីហនុ គឺជាខេត្តពីក្នុងចំណោមរាជធានីខេត្ត៤ផ្សេងទៀត ដែលត្រូវបានរកឃើញថា មានអត្រានៃការឆ្លងមេរោគអេដស៍ថ្មីខ្ពស់ជាងគេក្នុងចំណោមប្រជាជនដែលជាក្រុមប្រឈមមុខខ្ពស់រួមមាន បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកបម្រើក្នុងសេវាកម្សាន្ត និងអ្នកប្រើប្រាស់គ្រឿងញៀន។

លោកបានបន្តថា តាមការវិភាគក៏បានបង្ហាញថា កំណើននៃការឆ្លងមេរោគអេដស៍ថ្មីគឺស្ថិតក្នុងចំណោមបុរសនិងក្មេងប្រុស មានចំនួន៧៩%។ ក្នុងនោះ ៨៣%នៃអ្នកឆ្លងថ្មី គឺជាក្រុមប្រឈម ឬជាក្រុមប្រជាជនគន្លឹះ។

លោកបានបន្តថា ជាមួយគ្នានេះ ក្រុមបុរសរួមភេទជាមួយបុរសដែលជាយុវវ័យចំនួន៥០%ត្រូវបានរកឃើញថា មិនទទួលស្គាល់ថាខ្លួនជាអ្នកប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ឡើយ ដូច្នេះគប្បីត្រូវយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀត ក្នុងការពង្រីកសេវាគ្របដណ្តប់ និងអន្តរាគមន៍បង្ការឱ្យបានហ្មត់ចត់ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។








ដោយឡែក លោក ឈឹម យិនដារ៉េត អគ្គលេខាធិការ និងជាអ្នកនាំពាក្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានឲ្យដឹងដែរថា ប្រទេសកម្ពុជាមានអ្នកផ្ទុកមេរោគអេដស៍ចំនួនប្រមាណ ១២ ០០០ដែលមិនទាន់បានដឹងពីស្ថានភាពរបស់ខ្លួន។

ពាក់ព័ន្ធនឹង បញ្ហានេះ បុរសដែលស្រលាញ់ភេទដូចគ្នាមួយរូប ដែលបាននិយាយដោយសុំមិនបញ្ចេញអត្តសញ្ញាណ បានប្រាប់ថា ស្នេហ៍ស្មោះគឺជាប្រភពការពារដ៏មានតម្លៃសម្រាប់ការពារមេរោគនេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ លោកក៏ព្រួយបារម្ភចំពោះបញ្ហាលើដៃគូ។

លោកបានបន្តថា សព្វថ្ងៃនេះ លោកក៏នៅមិនទាន់បានស្វែងរកសេវាពិនិត្យជំងឺនេះដែរ ប៉ុន្តែទោះបីជាយ៉ាងណាលោកក៏ព្រួយបារម្ភអំពីករណីឆ្លងផងដែរ។

លោកបានបញ្ជាក់ថា ៖ «ខ្ញុំស្មោះនឹងគេ ប៉ុន្តែគេអាចនឹងមិនស្មោះនឹងខ្ញុំក៏មិនដឹង ប៉ុន្តែបើឆ្លងហើយ គឺមានតែតាមកម្មទៅចុះ»។

នៅពេលនេះនៅកម្ពុជាមានអ្នកផ្ទុកមេរោគអេដស៍សរុបប្រមាណជា ៧៦ ០០០ នាក់ និងមានអត្រាឆ្លងប្រមាណជា ១ ៤០០ នាក់ នៅក្នុងមួយឆ្នាំ ដោយនៅក្នុងនោះមានករណីស្លាប់ប្រមាណជា ១ ១០០ ករណី៕

> រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ និងខេត្តព្រះសីហនុ ត្រូវគេរកឃើញថាមានអត្រាឆ្លងរហូតដល់៧២ភាគរយ នៃការឆ្លងថ្មីនៅទូទាំងប្រទេស





# លោក ហាក់ គា ច្នៃសំបកដប កំប៉ុងទៅជាវត្ថុមានតម្លៃ



*អត្ថបទ៖អរិយបុត្រ*

សំបកដបដែលគេដឹងថា គឺជាសំរាមប្លាស្ទិកដែលនៅក្នុងមួយថ្ងៃៗសល់រាប់សិបគីឡូក្រាមនៅតាមធុងសំរាមនិងបោះចោលពាសវាលពាសកាល តែនៅពេលនេះវាកំពុងតែក្លាយទៅជាវត្ថុធាតុដើមដ៏មានតម្លៃសម្រាប់ច្រវាក់ផលិតកម្ម សិប្បកម្មកែច្នៃមួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិព្រៃទា២ សង្កាត់ចោមចៅ ពោលគឺនៅក្រោយបន្ទាយ៩១ នៅម្តុំពោចិនតុង រាជធានីភ្នំពេញ។

ពាក់ព័ន្ធនឹងផលិតកម្ម ការបែកគំនិតកែច្នៃក៏ដូចជាដើមទុន លោក ហាក់ គា ម្ចាស់សិប្បកម្មអំបោសដែលធ្វើពីសំរាមបានចែករំលែកនូវព័ត៌មានខ្លះៗប្រាប់អ្នកនាំសារដែលមានខ្លឹមសារដូចខាង ក្រោមនេះ៖

**តើលោកចាប់ផ្តើមអនុវត្តសកម្មភាពកែច្នៃនេះនៅពេលណាដែរហើយដោយសារមូលហេតុអ្វីដែរ?**

លោក ហាក់ គា៖ ខ្ញុំទើបតែបើកអាជីវកម្មកែច្នៃសំរាមសំបកដបធ្វើជាអំបោសនេះ ដំបូងនៅខែមីនា ឆ្នាំ២០២៣ នេះតែប៉ុណ្ណោះ ហើយឥឡូវឃើញមានការគាំទ្រច្រើន។ ខ្ញុំធ្វើដូចនេះដោយសារយើងចង់កែច្នៃរបស់ដែលគេបោះចោលនៅក្នុងស្រុកយើងឱ្យមានប្រយោជន៍ឡើងវិញ។ វត្ថុធាតុដើមសំខាន់ដែលយើងត្រូវការគឺមានដបអេតចាយ ដបទឹកសុទ្ធដែលគេបោះចោលលក់បានថោក។ យើងទិញក្នុងតំលៃមួយដែលគាត់លក់ឱ្យយើងបានស្រួល ហើយយើងយកមកកែច្នៃធ្វើជាអំបោស និងផលិតផលមួយចំនួនទៀតដោយរួមទាំងស្បូវពីសំរាមប្លាស្ទិកទាំងនេះផងដែរ។

**អាជីវកម្មរបស់លោកដំណើរការយ៉ាងណា ហើយផលិតផលទទួលបានការគាំទ្រប៉ុណ្ណាពីអ្នកប្រើប្រាស់?**

លោក ហាក់ គា៖ ក្រោយផលិតកម្មយើងដាក់ផលិតផលចូលទៅផ្សារយើងឃើញថា ពលរដ្ឋខ្មែរយើងចាប់អារម្មណ៍ច្រើន ហើយយើងគិតថា ផលិតផលយើងកំពុងតែទទួលបានការគាំទ្រច្រើនដែរ ព្រោះអាជីវកម្មយើងទើបតែចាប់ផ្តើមលក់ទេ ហើយបរិមាណក៏នៅមិនទាន់បានបូកសរុប។ ពេលបច្ចុប្បន្ននេះ អ្នកទិញអំបោសយើងយកទៅប្រើប្រាស់ គឺពួកគាត់មកទិញចំនួនច្រើន ដោយខ្លះម្នាក់៥ ម្នាក់១០ គឺគាត់ជួយយើង ជាជំហានដំបូង គាត់ជួយយើង គាត់សាកល្បងប្រើ ហើយយើងឃើញថា គាត់ជឿជាក់នៅលើផលិតផលរបស់យើង។

**តើនៅក្នុងសិប្បកម្មលោក មានបុគ្គលិក រឺកម្មករចំនួនប៉ុន្មាននាក់ដែរ?**

លោក ហាក់ គា៖ នៅទីនេះមានចំនួន ១៥នាក់ ហើយមានអ្នកនៅតាមផ្ទះមួយចំនួនទៀត ដែលគាត់អាចធ្វើនៅតាមផ្ទះបានខ្លួនគាត់ប្រហាក់ប្រហែល១៣គ្រួសារ នៅក្នុងនោះប្រុសមានតិចតួចទេ។ សម្រាប់ដើមទុនវិញវាប្រហាក់ប្រហែលជា៣ម៉ឺនដុល្លារដែរ ដោយប្រើប្រាស់ថវិការផ្ទាល់ខ្លួនរបស់ខ្ញុំតែម្តង។







**សព្វថ្ងៃលោកកែច្នៃសំរាមប្លាស្ទិកជាវត្ថុអ្វីខ្លះ?**

លោក ហាក់ គា៖ យើងអាចកែច្នៃទៅជាអំបោស ហើយនឹងអាចធ្វើជាស្បូវបាន ធ្វើបានជាជញ្ជាំងបានល្អហើយផលិតផលអំបោសយើងមានច្រើន យើងអាចបោសដៃក៏បាន ឈរបោសក៏បាន បោសពីងពាងក៏បាន បោសការ៉ូបន្ទប់ទឹកក៏បាន ពោលគឺយើងអាច បោសញីញក់បានម៉ាសេរី។ នៅក្នុងអំបោសមួយដើម ថ្លៃតែ១ម៉ឺនរៀលទេ ដោយយើងរៀបចំជូនគាត់ យើងអាចដឹកជូនផ្ទះដោយមិនគិតលុយថែមទៀតផង។ នៅពេលនេះការបោះដុំយើងអត់ទាន់មានទេ មានតែនៅទីតាំងមួយនេះ ហើយឥឡូវមានអ្នកចង់ជួយយើង គាំទ្រយើងគាត់ចង់យករបស់យើងម្តង១០ម្តង២០ គាត់យកទៅលក់បន្ត ហើយអ្នកខ្លះទៀតគាត់ក៏ជួយទិញសម្រាប់ដាក់នៅវត្ត ឬទីសាធារណៈដែរ។

**ពេលនេះប្រជាជនកំពុងចាប់អារម្មណ៍កាត់បន្ថយការប្រើប្រាស់សំរាមប្លាស្ទិក អនាគតអាចប៉ះពាល់ដល់អាជីវកម្មរបស់លោកដែរទេ?**

លោក ហាក់ គា ៖ កាកសំណល់ភាគច្រើនឥលូវនេះគេនាំគ្នាកែច្នៃច្រើន ទាំងអស់គ្នា ទាំងខ្ញុំទាំងគេនាំគ្នាចូលរួមទាំងអស់គ្នាអ៊ីចឹង ខ្ញុំជាផ្នែកមួយ អ្នកដទៃក៏ជាផ្នែកមួយ ហើយបើពលរដ្ឋយើងចេះទុកដាក់វេចខ្ចប់ត្រឹមត្រូវ យើងរួមគ្នាយើងអាចជួយកំចាត់សំរាមបំពុលបរិស្ថានបាន។

សំរាប់ខ្ញុំ អត់គិតថាប៉ះពាល់ទេ មានន័យថាបើគាត់ចង់ធ្វើអំបោសដែរ គាត់អាចមកមើលនៅកន្លែងនេះបាន គាត់អាចមកសាកល្បងបាន។ ឧបករណ៍យើងមានគ្រប់គ្រាន់សម្រាប់គាត់ប្រើប្រាស់។ ប្រសិនបើគាត់ចង់ធ្វើខ្លួនឯងគាត់អាចអញ្ជើញមកទីនេះបាន គាត់ធ្វើចុះ មានន័យថាយើងណែនាំគាត់ធ្វើទាំងអស់យើងអត់មានលាក់បាំងគាត់កន្លែងណាមួយទេ ព្រោះអីបុគ្គលិកនៅទីនេះក៏ដូចគ្នាគឺចេះទាំងអស់។

> ខ្ញុំធ្វើដូចនេះ ដោយសារយើងចង់កែច្នៃរបស់ដែលគេបោះចោលនៅក្នុងស្រុកយើងឱ្យមានប្រយោជន៍ឡើងវិញ។ វត្ថុធាតុដើមសំខាន់ដែលយើងត្រូវការគឺមានដបអេតចាយ ដបទឹកសុទ្ធដែលគេបោះចោលលក់បានថោក។

**តើលោកអាចប្រាប់ពីខ្សែច្រវាក់ផលិតកម្មនៃការផលិត ការចាប់ផ្តើមដំបូងនៃការផលិតអំបោសមួយដើមថាត្រូវចាប់ផ្តើមពីកន្លែងណាខ្លះ?**

លោក ហាក់ គា៖ ពីដំបូងយើងត្រូវកាត់គូទដបជាមុនសិន ហើយយើងយកទៅទាញឱ្យចេញជាខ្សែ រួចយកទៅបញ្ចូលក្នុងពុម្ព ហើយតម្រឹមខ្នាតឱ្យត្រូវនឹងខ្នាតមួយ បានខ្នាតនឹងហើយយកវាទៅស្រុះឱ្យជ័រខ្សែចេញត្រង់ ហើយយើងកាត់ខ្សែនឹងចេញ យើងយកខ្សែនឹងចងជាមួយអំបោស ហើយការចង គឺចង២ជាន់។ ចងពីខាងក្នុងហើយត្រូវចងលួសពីខាងក្រៅទៀត ហើយយើងត្រូវស្រោប ហើយផ្តុំកំដៅគៀបវា អ៊ីចឹងអំបោសហ្នឹងលួសខាងក្នុងវាអត់ត្រូវជាមួយនឹងរបស់អ្វីផ្សេងៗ ដែលធ្វើឱ្យវាដាច់ទេ គឺអំបោសនេះប្រើធន់ណាស់។

ការងារទាំងអស់នៃច្រវាក់ផលិតកម្ម គឺយើងប្រើតែ ម៉ូទ័រ២សំរាប់បង្វិលបញ្ចូលពុម្ពទេ ព្រោះការងារនឹងច្រើន យើងមិនអាចធ្វើដោយដៃបាន ហើយមួយទៀតនៅពេលដែលយើងផ្តុំគៀប យើងត្រូវការកំដៅ អ៊ីចឹង!យើងមិនអាចធ្វើដោយដៃបាននោះទេ យើងប្រើប្រាស់ម៉ាស៊ីនផ្តុំកំដៅ៕

# សង្ខេបព្រឹត្តិការណ៍ក្នុងស្រុក

## គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងកម្មវិធីជាតិក្របខណ្ឌកិច្ចគាំពារសង្គមក្នុងកញ្ចប់គ្រួសារ



*អត្ថបទ៖ អមរិន្ទ ដានុត*

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសឱ្យអនុវត្តជាផ្លូវការនូវគោលការណ៍ណែនាំនេះ នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ ដែលជាបណ្តុំនៃកម្មវិធីជាតិជំនួយសង្គម ដោយសំយោគកម្មវិធីដែលមានស្រាប់ រួមផ្សំនឹងកម្មវិធីថ្មីបន្ថែម ដើម្បីទ្រទ្រង់ជីវភាពប្រជាពលរដ្ឋដោយប្រកាន់ភ្ជាប់នូវគោលការណ៍បរិយាបន្ន និងសមធម៌ ព្រមទាំងការចៀសវាងបាននូវការធ្លាក់ចុះយ៉ាងគំហុកនៃប្រាក់ចំណូលសម្រាប់គ្រួសារដែលមានបណ្ណសមធម៌ទាំងអស់ ក៏ដូចជាគិតគូរដល់សមាជិកគ្រួសារដែលរស់នៅជាមួយមេរោគនិងជំងឺអេដស៍។

កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនេះ នឹងផ្តល់ប្រយោជន៍ដល់គ្រួសារមានបណ្ណសមធម៌ប្រមាណ ៧០ម៉ឺនគ្រួសារ ស្មើនឹង ២,៨លាននាក់ ដោយគ្រោងនឹងចំណាយថវិកាប្រមាណ ៦៧៤,៥ប៊ីលានរៀល ស្មើនឹង ១៦៥លានដុល្លារក្នុងឆ្នាំ២០២៤។ ឈរលើស្មារតី «មិនបោះបង់ចោលពលរដ្ឋខ្មែរណាម្នាក់» ការពង្រឹងប្រព័ន្ធគាំពារសង្គម គឺជាកិច្ចការអាទិភាពទី៤ នៅក្នុងបញ្ចកោណទី១ នៃយុទ្ធបញ្ចកោណ-ដំណាក់កាលទី១ ស្តីពី ការអភិវឌ្ឍមូលធនមនុស្សដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការកសាង និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ និងសង្គតិភាព ទាំងក្នុងប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម៕

## ពិធីបិទបុណ្យសមុទ្រលើកទី១០ ជុំទី៣ ប្រារព្ធដោយជោគជ័យ

*អត្ថបទ៖ អមរិន្ទ ដានុត*

ពិធីបិទបុណ្យសមុទ្រលើកទី១០ ជុំទី៣ ក្រោមប្រធានបទ «ទាំងអស់គ្នាដើម្បីទេសចរណ៍» បានប្រារព្ធធ្វើឡើងរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២ និងទី៣ ខែធ្នូ នានៅខេត្តកែប ដោយមានភ្ញៀវជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ។

ថ្លែងនៅក្នុងពិធីបិទបុណ្យសមុទ្រលើកទី១០ លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានឱ្យដឹងថា រាជរដ្ឋាភិបាលបានកំណត់ប្រារព្ធពិធីបុណ្យសមុទ្រ ដែលមិនត្រឹមតែរួមចំណែកដល់ការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្ររបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមដល់ការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលផ្តោតការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយចីរភាព និងបរិយាបន្ន។

លោកក៏បានលើកពីលក្ខណៈពិសេស ៣យ៉ាង ក្នុងចំណោមលក្ខណៈពិសេសជាច្រើនរបស់វិស័យទេសចរណ៍ ដូចជា៖ (១) វិស័យទេសចរណ៍នាំឱ្យមានការអភិវឌ្ឍនៅនឹងកន្លែង (២) ការរីកចម្រើនខាងវិស័យទេសចរណ៍បណ្តាលឱ្យវិស័យដទៃៗទៀតមានការរីកចម្រើនផងដែរ (៣) វិស័យទេសចរណ៍ជួយលើកកម្ពស់កិត្តិនាមរបស់ប្រទេសជាតិ ក៏ដូចជាមរណីយដ្ឋានគោលដៅនានា តាមរយៈការបង្កើនភាពជឿជាក់ និងទាក់ទាញដល់បណ្តាភ្ញៀវជាតិ និងអន្តរជាតិមកពីគ្រប់ទិសទី៕



## សៀវភៅ «កេរតំណែលស្នាដៃម្ហូបខ្មែរ»ឈ្នះពានរង្វាន់ទូរទស្សន៍ម្ហូបអាហារល្អដាច់គេនៅលើពិភពលោក

សៀវភៅ «កេរដំណែលស្នាដៃម្ហូបខ្មែរ» (The Taste of Angkor) ដែលរៀបចំចងក្រង និងបោះពុម្ពផ្សាយដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាផ្នែកមួយនៃការទូតអាហារ របស់ក្រសួងបានទទួលជ័យលាភីជាថ្មីម្តងទៀតគឺ «ពានរង្វាន់ទូរទស្សន៍ម្ហូបអាហារល្អដាច់គេលើពិភពលោក» (Best Television Awards in the World)» នៅក្នុងកម្មវិធីប្រកួតពានរង្វាន់សៀវភៅមុខម្ហូបពិភពលោក ប្រចាំឆ្នាំនេះ (The Gourmand World Cookbook Awards) ដែលបានប្រារព្ធធ្វើឡើងពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុងរីយ៉ាត ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ហើយកម្មវិធីនេះ ត្រូវបានរៀបចំឡើងព្រមគ្នានៅក្នុងពិធីបុណ្យអាហារសាអូឌីត (Saudi Feast Food Festival)។

## សៀវភៅ «សោយ» ទទួលបានពានរង្វាន់អូស្ការ



«សោយ» សៀវភៅធ្វើម្ហូបល្អបំផុតនៅលើពិភពលោក ដែលជាស្នាដៃរបស់ខ្មែរ បានទទួលពានរង្វាន់ Gourmand Award ដែលសារព័ត៌មានអន្តរជាតិដាក់រហស្សនាមថាជា «ពានរង្វាន់អូស្ការ» ក្នុងវិស័យពានរង្វាន់ធ្វើម្ហូបអាហារ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅប្រទេស អារ៉ាប៊ីសាអូឌីត។

ដំណើរស្រាវជ្រាវលើសៀវភៅ «សោយ» មរតករសជាតិពីព្រះរាជដំណាក់ខ្មែរ បាននាំឱ្យម្ចាស់សៀវភៅ «សោយ» ស្វែងយល់បន្ថែមអំពីសម្តេច ព្រះរាជកន្និដ្ឋានរោត្តម រស្មីសោភ័ណ។ ទ្រង់បានលះបង់អស់ពីដួងចិត្ត និងរួមចំណែកក្នុងការងារអប់រំស្ត្រី ការងារមនុស្សធម៌ សប្បុរសធម៌ និងជាពិសេសការងាររបស់ទ្រង់ក្នុងការអភិរក្ស និងលើកស្ទួយសិល្បៈម្ហូបខ្មែរអំឡុងឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៧០។

ស្នាដៃសៀវភៅមួយនេះនឹងក្លាយជាសម្បត្តិជាតិរួមមួយដែលនាំឱ្យប្រជាជនខ្មែរគ្រប់រូបមានមោទកភាពចំពោះសិល្បៈនៃការធ្វើម្ហូបដ៏អស្ចារ្យរបស់ខ្មែរ។

## កម្ពុជា ប្រារព្ធព្រះរាជពិធីបុណ្យអុំទូក ក្រោយខកខាន៣ឆ្នាំ

ក្រោយពីខកខានប្រារព្ធព្រះរាជពិធីបុណ្យអុំទូកបណ្តែតប្រទីបនិងសំពះព្រះខែ អកអំបុករយៈពេល៣ឆ្នាំមកហើយ នៅឆ្នាំ២០២៣នេះ រាជរដ្ឋាភិបាលបានរៀបចំប្រារព្ធព្រះរាជពិធីបុណ្យនេះ យ៉ាងសប្បាយរីករាយ ដោយក្នុងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២៦ដល់២៨ ខែវិច្ឆិកា មានអ្នកដើរកម្សាន្តនៅរាជធានីភ្នំពេញជាង៥លាននាក់ និងនៅតាមបណ្តាខេត្តផ្សេងៗជាច្រើនទៀត។

នេះគឺជាការបើកទំព័រថ្មីមួយសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ខណៈដែលរាជរដ្ឋាភិបាលបានផ្អាកប្រារព្ធព្រះរាជពិធីបុណ្យអុំទូក ដោយតែការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩។

ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៣នេះ បានចូលរួមចំណែកយ៉ាងខ្លាំង ក្នុងការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលរួមទស្សនា។





# ព្រឹត្តិការណ៍អន្តរជាតិ

## នាយករដ្ឋមន្ត្រីអ៊ីស្រាអែល លោក Netanyahu នឹងត្រូវបានកាត់ទោសជាឧក្រិដ្ឋជនសង្គ្រាម



ប្រធានាធិបតីតួកគី លោក Recep Tayyip Erdogan នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០២៣ បាននិយាយថា នាយករដ្ឋមន្ត្រីអ៊ីស្រាអែល លោក Benjamin Netanyahu នឹងត្រូវកាត់ទោសជាឧក្រិដ្ឋជនសង្គ្រាមជុំវិញការវាយប្រហាររបស់អ៊ីស្រាអែលដែលកំពុងបន្តលើតំបន់ Gaza Strip និងបានរិះគន់ប្រទេសលោកខាងលិចដែលគាំទ្រអ៊ីស្រាអែល។នេះបើយោងតាមការចេញផ្សាយដោយ ទីភ្នាក់ងារសារព័ត៌មាន AFP។

គួររំលឹកផងដែរថា ប្រទេសតួកគីដែលគាំទ្រដំណោះស្រាយរដ្ឋពីរចំពោះជម្លោះដែលមានអាយុកាលរាប់ទសវត្សរ៍នោះ បានរិះគន់អ៊ីស្រាអែលយ៉ាងចាស់ដៃ ចំពោះប្រតិបត្តិការយោធារបស់អ៊ីស្រាអែលនៅហ្គាហ្សា។មនុស្សជាង ១៥,៥០០ នាក់ ត្រូវបានសម្លាប់នៅក្នុងការទម្លាក់គ្រាប់បែកតាមអាកាសរបស់អ៊ីស្រាអែល។នៅក្នុងសុន្ទរកថាទៅកាន់កិច្ចប្រជុំគណៈកម្មាធិការ នៃអង្គការសហប្រតិបត្តិការឥស្លាម (OIC) នៅទីក្រុងអ៊ីស្តង់ប៊ុល លោក Erdogan បាននិយាយថា ប្រទេសលោកខាងលិចដែលគាំទ្រអ៊ីស្រាអែលកំពុងផ្តល់ «ការគាំទ្រដោយគ្មានលក្ខខណ្ឌក្នុងការសម្លាប់ទារក» ហើយពួកគេមានការជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មមួយនេះ។ *ប្រភព៖ ហ្វ្រេសញូវ*

## ប៉ាគីស្ថាន ក្លាយជាប្រទេសដំបូងគេនៅអាស៊ីខាងត្បូងដែលចេញសញ្ញាបណ្ណយេនឌ័រសម្រាប់ជួយដល់ស្ត្រីរងគ្រោះ



ប្រទេសប៉ាគីស្ថានក្លាយជាប្រទេសដំបូងគេនៅតំបន់អាស៊ីខាងត្បូង ដែលបានដាក់ចេញនូវ «សញ្ញាបណ្ណយេនឌ័រ» ឬហៅម៉្យាងទៀតថា «មូលបត្របំណុលយេនឌ័រ» ក្នុងគោលបំណងប្រមូលប្រាក់ចំនួន ៨,៧ លានដុល្លារអាមេរិក ដើម្បីផ្តល់ប្រាក់កម្ចីខ្នាតតូចដល់ស្ត្រីប្រហែលបីម៉ឺននាក់ ដែលភាគច្រើនរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់ធ្ងន់ធ្ងរក្នុងឆ្នាំ២០២២។

គួរដឹងដែរថា សញ្ញាប័ណ្ណបំណុលសម្រាប់ស្ត្រីនេះត្រូវបានសហការដាក់ចេញដោយអង្គការមិនរកប្រាក់ចំណេញប៉ាគីស្ថានមួយឈ្មោះថា Kashf Foundation និងក្រុមហ៊ុន InfraZamin Pakistan គាំទ្រដោយគម្រោង InfraCo Asia Investments និងក្រុមហ៊ុន Karandaaz Pakistan ។ សម្រាប់សញ្ញាប័ណ្ណបំណុលនេះក្រុមហ៊ុនចេញផ្សាយនឹងដាក់លក់នៅលើទីផ្សារភាគហ៊ុន។

លោក ហ្សាហ្សាដ អ៊ីស្បាល (Shahzad Iqbal) ប្រធានផ្នែកហិរញ្ញវត្ថុរបស់អង្គការ Kashf Foundation បានលើកឡើងថា ៖ «សញ្ញាប័ណ្ណនេះមានគោលបំណងផ្តល់ប្រាក់កម្ចីដល់ស្ត្រីដែលរងផលប៉ះពាល់ដោយទឹកជំនន់កាលពីឆ្នាំមុន ដែលអាចឱ្យពួកគេបង្កើនភាពធន់ និងការការពារប្រឆាំងនឹងគ្រោះមហន្តរាយនាពេលអនាគត»។ លោកបានបន្តថា ៖ «មូលបត្របំណុលនេះមានតម្លៃ ៨,៧ លានដុល្លារ ហើយនឹងមានរយៈពេល ៣ ឆ្នាំ។ ហើយវាត្រូវបានរចនាឡើងជាពិសេសសម្រាប់ស្ត្រីតែប៉ុណ្ណោះ ដូច្នេះហើយទើបយើងដាក់ឈ្មោះវាថា «សញ្ញាប័ណ្ណយេនឌ័រ»៕ *ប្រភព៖ CPA*

## ហ្វីលីពិនព្រួយបារម្ភការរីករាលដាលនៃមេរោគអេដស៍

ចាប់តាំងពីឆ្នាំ ២០០៣ មកដល់ពេលនេះ មេដឹកនាំហ្វីលីពីនបានសំដែងការចាប់អារម្មណ៍កាន់តែខ្លាំងឡើងទាក់ទងនឹង ការកើនឡើងដែលមិនអាចទទួលយកបាននៃករណីមេរោគអេដស៍។

មានសេចក្តីរាយការណ៍ថា អត្រានៃការស្លាប់ដោយសារមេរោគអេដស៍និងជំងឺអេដស៍នៅក្នុងប្រទេសហ្វីលីពីនកំពុងកើនឡើងដែលផ្ទុយគ្នានឹងស្ថានភាពនៅប្រទេសភាគច្រើននៃពិភពលោកដែលអត្រានៃការឆ្លងមានការថយចុះ ។

អង្គការសហប្រជាជាតិ ទទួលបន្ទុកជំងឺអេដស៍ (UN AIDS ) ប្រទេសហ្វីលីពីនបានបង្ហោះករណីមេរោគអេដស៍ដែលមានការកើនឡើងលឿនបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ។

អង្គការនេះបានអះអាងថា អត្រានៃការឆ្លងមេរោគអេដស៍នៅហ្វីលីពីនមានកំណើនរហូតដល់ទៅ ២៣៧ ភាគរយនៃការឆ្លងមេរោគអេដស៍ប្រចាំឆ្នាំ ចាប់តាំងពីពីឆ្នាំ ២០១០ ដល់ ២០២០ ហើយ ទន្ទឹមនឹងនេះ ការស្លាប់ដែលទាក់ទងនឹងជំងឺអេដស៍បានកើនឡើង ៣១៥ ភាគរយ។ នៅក្នុងខែមិថុនា ឆ្នាំ ២០២៣ ក្រសួងសុខាភិបាលហ្វីលីពិនបានរាយការណ៍ថា មានយុវជនដែលមានផ្ទុកមេរោគអេដស៍ចំនួនរហូតដល់ ៤៦៦ នាក់ត្រូវបានរកឃើញដោយពួកគេមានអាយុពី ១៥ ទៅ ២៤ ឆ្នាំ នៅក្នុងនោះ ៩៤ ភាគរយជាបុរស ខណៈដែលនារីមានត្រឹមតែ ៦ភាគរយជាស្ត្រី។ ប្រភពដដែលបានអះអាងថា មូលហេតុនៃការឆ្លងត្រូវបានគេដឹងថា ៩៩ ភាគរយគឺឆ្លងតាមការរួមភេទ ហើយភាគរយខ្ពស់បំផុតគឺនៅក្នុងចំណោមក្រុមបុរសស្រលាញ់បុរស។ *(ប្រភព៖ RVA Khmer )*

## ប្រទេសអ៊ុយក្រែន សង្ស័យរុស្ស៊ីបំពុលភរិយាប្រមុខចារកម្ម

ទីក្រុងគៀវ សង្ស័យទីក្រុងមូស្គូ ថា បានបំពុលភរិយារបស់ប្រមុខចារកម្មអ៊ុយក្រែន លោកគីរីឡូ ប៊ូដានូវ ដោយសារជាបារ៉ត និងអាសេនិក។ លោកស្រី ម៉ារីយ៉ាណា ប៊ូដាណូវ៉ា ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ និងទទួលការព្យាបាលជាងមួយសប្តាហ៍មកហើយ។ ចំណែកលោកគីរីឡូ ប៊ូដានូវ បានគេចរួចពីការប៉ុងប៉ងធ្វើឃាត ១០ដងមកហើយដែរ។

លោកអន់ឌ្រីអ៊ី លូសូវ អ្នកនាំពាក្យនាំពាក្យភ្នាក់ងារចារកម្មយោធាអ៊ុយក្រែន បានថ្លែងកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ថា ទីក្រុងគៀវ បានសង្ស័យទីក្រុងមូស្គូ បំពុលភរិយាមេដឹកនាំចារកម្មយោធាអ៊ុយក្រែន លោកគីរីឡូ ប៊ូដានូវ។ លោកបាននិយាយថា ៖ «នេះគឺជាសមតិកម្មសំខាន់ និងអះអាងថា នេះមិនមែនជាគ្រោះថ្នាក់ ប៉ុន្តែគឺជាការបំពុលដែលពិចារណាថា គឺជាការពុលសារធាតុលោហៈធ្ងន់ មានជាអាទិ៍ បារ៉ត និងជាតិអាសេនិក»។

បើយោងតាមលោកអន់ឌ្រីអ៊ី លូសូវ នេះគឺច្បាស់ណាស់លោកស្រី ម៉ារីយ៉ាណា ប៊ូដានូវ៉ា និងប្តីរបស់លោកស្រី គឺជាគោលដៅវាយប្រហារ។ អ្នកនាំពាក្យរូបនេះ បានវាយតម្លៃថា ៖ «រឿងសាមញ្ញគឺថា វាមិនអាចទៅរួចនឹងវាយប្រហារផ្ទាល់ទៅលើមេបញ្ជាការ ប៊ូដានូវ តាមរបៀបនេះ ដូច្នេះ វាក៏ធ្លាក់លើភរិយាលោក»។

នៅពេលនេះ រុស្ស៊ីមិនបានប្រតិកម្មចំពោះការចោទប្រកាន់នេះទេ។ លោកអន់ឌ្រីអ៊ី លូសូវ បញ្ជាក់ថា លោកស្រី ម៉ារីយ៉ាណា ប៊ូដានូវ៉ា ដែលជាទីប្រឹក្សារបស់ចៅហ្វាយក្រុងគៀវ លោកវីតាលី ក្លីត្ស្គូ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យជាង១សប្តាហ៍ មកហើយ។ មើលដោយរូបភាព ជីវិតរបស់លោកស្រីមិនស្ថិតនៅក្នុងគ្រោះថ្នាក់ទេ៕ *ប្រភព៖ RVA Khmer*



# «យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» ឆ្នាំ២០២៣-២០២៨ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ដាក់ឱ្យអនុវត្ត




*អត្ថបទ៖ អមរិទ្ធិ ដានុត*

អនុលោមតាម «យុទ្ធសាស្ត្របញ្ចកោណ» ដំណាក់កាលទី១ និងឈរលើមូលដ្ឋាននៃគោលនយោបាយ និងយុទ្ធសាស្ត្រជាតិដែលមានជាធរមាន ព្រមទាំងក្របខណ្ឌអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ក្រសួងបរិស្ថានបានរៀបចំ «យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» ឆ្នាំ២០២៣-២០២៨។

«យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» នេះរៀបចំឡើងក្នុងគោលបំណងតម្រង់ទិស និងសុក្រឹតកម្មបរិស្ថានកិច្ច ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សំដៅសម្រេចគោលដៅយុទ្ធសាស្ត្របញ្ចកោណ គឺ «ជាប្រទេសអព្យាក្រឹតកាបូន និងមានគម្របព្រៃឈើ៦០ភាគរយ នៅឆ្នាំ២០៥០»។

យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាននេះ ត្រូវបានក្រសួងបរិស្ថានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣។



លោក អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានលើកឡើងថា លោកមានជំនឿយ៉ាងមុតមាំថាអង្គភាពក្រោមឱវាទក្រសួងនឹងរួមសាមគ្គីគ្នា ព្រមទាំងសហការជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនក្នុងការអនុវត្ត «យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨» ប្រកបដោយជោគជ័យដើម្បីជាឧត្តមប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់ និងលើកតម្កើងកិត្យានុភាពប្រទេសកម្ពុជាលើឆាកអន្តរជាតិ។

លោកមានប្រសាសន៍ថា ៖ «រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចប្រកាសឱ្យប្រើប្រាស់យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានថ្មីឆ្នាំ២០២៣-២០២៨ ដោយឈរលើអាទិភាពចម្បង៣គឺ៖ ស្អាត បៃតង និងចីរភាព ដែលឆ្ពោះទៅរកការសម្រេចបាននូវអព្យាក្រឹតភាពកាបូន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣»។

លោកបានបន្តថា ៖ «នាវាបរិស្ថានផ្តើមចេញដំណើរហើយ ដោយមានបំពាក់នូវផែនទីចង្អុលផ្លូវ គឺយុទ្ធសាស្ត្រចក្រា ហើយឈរលើផែនទីចង្អុលផ្លូវមួយនេះ វិស័យបរិស្ថានរបស់យើងទាំងអស់គ្នា នឹងទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០»។

ឈរលើភាពស្អាត ដោយផ្តើមចេញពីការគាំទ្ររបស់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ ព្រះសង្ឃ កម្មករ កម្មការិនី ប្រជាពលរដ្ឋកម្ពុជា ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកដោយបេះដូង ធ្វើឱ្យសាលារៀនស្អាត វត្តអារាមស្អាត ភូមិឋានស្អាត សហគមន៍ស្អាត និងទីក្រុងស្អាត គឺជាភាពជោគជ័យទាំងអស់គ្នា ហើយភាពស្អាតទាំងក្នុងនិងក្រៅនេះ ប្រៀបដូចជាស្នាមញញឹមស្រស់ស្អាតបំផុតក្នុងការទាក់ទាញភ្ញៀវទេសចរអន្តរជាតិឱ្យមកទស្សនាប្រទេសកម្ពុជា។

> នាវាបរិស្ថានផ្តើមចេញដំណើរហើយ ដោយមានបំពាក់នូវផែនទីចង្អុលផ្លូវ គឺយុទ្ធសាស្ត្រចក្រា ហើយឈរលើផែនទីចង្អុលផ្លូវមួយនេះ វិស័យបរិស្ថានរបស់យើងទាំងអស់គ្នា នឹងទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០

ទាក់ទងនឹងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាននេះដែរ ក្រសួងបរិស្ថានជំរុញការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាលដល់មន្ទីរបរិស្ថាន រដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងគោលនយោបាយគ្រប់គ្រងសំណល់រឹង, សហការចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ២០២០-២០៣០។

នយោបាយឈ្នះឈ្នះរបស់អតីតនាយករដ្ឋមន្ត្រី សម្តេចតេជោ ហ៊ុន សែន បានធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុងក្នុងរយៈពេលជាង២៥ឆ្នាំចុងក្រោយនេះ។ ប្រកាសនេះបានបង្ហាញលក្ខណៈគ្រប់គ្រាន់ និងជាកាលានុវត្តភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាលប្រកបដោយជោគជ័យ និងប្រសិទ្ធភាពជាមួយសមិទ្ធផលជាច្រើនលើគ្រប់វិស័យ។








សូមបញ្ជាក់ដែរថា ជាមួយនឹងយុទ្ធសាស្ត្រចក្រា ក្រសួងបរិស្ថាន បាននិងកំពុងរៀបចំយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» នៅទូទាំងប្រទេស ដោយមានការចូលរួមពីសិស្សានុសិស្សចំនួនជាង២លាននាក់។ យុទ្ធនាការនេះមិនត្រឹមតែមានការគាំទ្រ និងចូលរួមពីសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែក៏មានការគាំទ្រយ៉ាងពេញទំហឹងពីដៃគូអភិវឌ្ឍន៍ ម្ចាស់រោងចក្រ និងកាកបាទក្រហមកម្ពុជាផងដែរ។



ក្រសួងបរិស្ថាន ក៏បានដាក់ចេញនូវវិធានការចំនួន៤ សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ឱ្យមានប្រសិទ្ធភាព ដែលក្នុងនោះទី១ គឺការអនុវត្តច្បាប់១០០% មិនអត់ឱនចំពោះឧក្រិដ្ឋកម្មធនធានធម្មជាតិ ទី២ ពង្រឹងសហការឱ្យកាន់ស្អិតរមួត ជាមួយអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ ទប់ស្កាត់បទល្មើសធនធានធម្មជាតិ ទី៣ សហការជាមួយអង្គភាពប្រឆាំងអំពើពុករលួយ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីពង្រឹងការអនុវត្តច្បាប់បន្ថែមទៀត និងទី៤ បង្កើតផែនការដាំដើមឈើឡើងវិញ និងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។

### ពលរដ្ឋមានតួនាទីយ៉ាងណាក្នុងការចូលរួមកាត់បន្ថយការប្រើថង់ប្លាស្ទិក?

តាមរយៈក្រសួងបរិស្ថាន គិតមកដល់ឆ្នាំ២០២២ នៅទូទាំងពិភពលោក បានផលិត និងប្រើប្រាស់សម្ភារ ប្លាស្ទិក ប្រមាណ ៩,៥ពាន់លានតោន ក្នុងអត្រាកំណើន ៣% ជារៀងរាល់ឆ្នាំ។ ការប្រើប្រាស់សម្ភារប្លាស្ទិកនៅលើពិភពលោក បាននិងកំពុងបង្កជាបញ្ហាដល់បរិស្ថាន និងសុខុមាលភាពមនុស្សសត្វលើភពផែនដី។



ក្រសួងបានបន្តថា សំណល់ប្លាស្ទិកដែលប្រើរួចហើយត្រូវបានបោះចោលមានតែប្រមាណ៩% នៃបរិមាណសំណល់ប្លាស្ទិក សរុបលើពិភពលោកប៉ុណ្ណោះ ដែលបានយកមកកែច្នៃផលិតឡើងវិញ រីឯ៩១%ទៀត ត្រូវបានយកទៅទីលានទុកដាក់សំរាម ឬដុតចោល និងចោលរាយប៉ាយតាមទីសាធារណៈ ធ្លាក់ចូលទៅក្នុងប្រភពទឹកហូរចាក់ចូលទៅក្នុងសមុទ្រ ប្រមាណជាង ៨លានតោនក្នុង១ឆ្នាំ។

ប្រជាជនកម្ពុជាម្នាក់ប្រើថង់ប្លាស្ទិកជាមធ្យម៤ថង់ក្នុង១ថ្ងៃ គឺសរុបថង់ប្លាស្ទិក ប្រើទូទាំងប្រទេសក្នុង១ថ្ងៃ ប្រមាណ ៥៥លានថង់ ដែលគិតជាទម្ងន់ប្រមាណ ២៨០ តោន។ ក្រៅពីថង់ប្លាស្ទិក នៅមានសម្ភារប្លាស្ទិកបម្រើផ្នែកអាហារ និងភេសជ្ជៈដូចជា៖ ចាន ប្រអប់ស្នោរ កែវ ស្លាបព្រាសម កាំបិត បំពង់បឺត ប្រអប់ជ័រ ដែលកំពុងពេញនិយមប្រើប្រាស់កាន់តែច្រើនឡើងៗ។

អ្នកស្រី សោម ផានិត អាយុ៤២ឆ្នាំ ជាស្ត្រីមេផ្ទះ និងជាបុគ្គលិកក្រុមហ៊ុនផងដែរ បានប្រាប់ឱ្យដឹងថា អ្នកស្រីដឹងពីផលប៉ះពាល់របស់ប្លាស្ទិក ប៉ុន្តែនៅតែប្រើវា ជាពិសេសពេលទៅផ្សារទិញម្ហូប និងអាហារជាដើម ព្រោះអ្នកស្រីតែងតែភ្លេចយកកន្ត្រក ឬថង់ក្រណាត់ដើម្បីដាក់ជំនួសថង់ប្លាស្ទិក។

អ្នកស្រី បាននិយាយថា៖ «ខ្ញុំមានថង់ក្រណាត់ដែលគេហៅថា ថង់បរិស្ថាន តែខ្ញុំចេះតែភ្លេចយកតាមខ្លួនពេលទៅផ្សារទិញម្ហូប ឬអីវ៉ាន់ផ្សេងៗ។ ចឹង គឺចៀសមិនផុតពីការប្រើថង់ប្លាស្ទិកដដែល។ ខ្ញុំដឹងថាមិនល្អ តែដោយសារមិនមានជម្រើសផ្សេង តែខ្ញុំក៏មិនមែនប្រើថង់ប្លាស្ទិកច្រើនលើសលុបនោះទេ»។



កញ្ញា វណ្ណ សុជាតិ អ្នកលក់អនឡាញ បានប្រាប់ឱ្យដឹងថា នាងដឹងពីផលប៉ះពាល់នៃប្លាស្ទិក ហើយនាងក៏បានចូលរួមជាច្រើនក្នុងការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ទោះបីជានាងជាអ្នកលក់អនឡាញដែលត្រូវការប្រើថង់ច្រើនក៏ដោយ។

កញ្ញាបានប្រាប់ថា ៖ «ខ្ញុំមានដបទឹកជាប់ខ្លួនជានិច្ច សម្រាប់ទិញកាហ្វេ ឬភេសជ្ជៈផ្សេងៗ ដោយខ្ញុំមិនដែលទិញដាក់ដបជ័រ ឬកំប៉ុងជ័រនោះទេ ហើយពេលទៅផ្សារគឺខ្ញុំមានថង់បរិស្ថានសម្រាប់ដាក់ម្ហូបអាហារមកវិញផងដែរ»។

កញ្ញាវណ្ណសុជាតិបានបញ្ជាក់ដែរថា ទោះបីជាគាត់បានចូលរួមតិចតួចក៏ដោយ តែក៏ជាចំណែកមួយក្នុងការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកផងដែរ ហើយសុជាតិ ក៏បាននិងកំពុងព្យាយាមនៅក្នុងការកាត់បន្ថយឱ្យបានច្រើនជាងនេះទៀតដែរ៕



# ក្រសួងសម្រាប់គោលលិទ្ធិនៃជំនឿ លើកទឹកចិត្តម្ដាយមានកូនតែគ្មានស្វាមីទទួលអគ្គសញ្ញា

ក្រសួងសម្រាប់គោលលិទ្ធិនៃជំនឿ បានចេញលិខិតឆ្លើយតបទៅនឹងសំណួររបស់លោកអភិបាលព្រះសហគមន៍នៅសាធារណរដ្ឋដូមីនីកាំងនៃទ្វីបអាមេរិកខាងជើង អំពីការទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ដក្នុងអភិបូជារបស់អ្នកម្ដាយដែលមានកូន តែគ្មានប្ដី (Single mother)។ ពួកនាងបានបដិសេធទទួលព្រះកាយព្រះគ្រីស្ត ដោយសារការភ័យខ្លាចចំពោះអ្នកណែនាំព្រះសហគមន៍។

លិខិតនេះបានចុះហត្ថលេខាដោយ លោកកាឌីណាល់ វីកទ័រ ម៉ានូអែល ហ្វេរណាន់ដេស អធិបតីក្រសួងសម្រាប់គោលលិទ្ធិនៃជំនឿ កាលពីថ្ងៃទី១៣ ខែធ្នូ ហើយត្រូវបាននាំទីកង់ញូវចុះផ្សាយនៅថ្ងៃបន្ទាប់។

ក្នុងលិខិតនោះបានបញ្ជាក់ថា ស្ត្រីនៅក្នុងស្ថានភាពបែបនេះ ប្រឈមមុខនឹងការលំបាករួចទៅសម្រាប់ការជ្រើសរើសជីវិត ហើយពួកនាងគួរត្រូវបានលើកទឹកចិត្ត ដោយអំណាចនៃការសង្គ្រោះ។

នេះជាលិខិតរបស់លោក កាឌីណាល់ វីកទ័រ ម៉ានូអែល ហ្វេរណាន់ដេស អធិបតីក្រសួងសម្រាប់គោលលិទ្ធិនៃជំនឿ ផ្ញើជូនលោកអភិបាលរ៉ាម៉ុន អាល់ហ្វ្រេដូ ដឺឡាគ្រូស បាល់ដឺ អភិបាលនៃភូមិភាគសាន់ហ្វ្រាន់ស៊ីស្កូនៅម៉ូកូវីស (សាធារណៈរដ្ឋដូមីនិកាំង)៕



**ក្រសួងសម្រាប់គោលលិទ្ធិនៃជំនឿ**
**លិខិតផ្ញើជូន**
**លោកអភិបាល រ៉ាម៉ុន អាល់ហ្វ្រេដូ ដឺ ឡា គ្រូស បាល់ដឺរ៉ា**
(Reverend Ramón Alfredo de la Cruz Baldera)
**អភិបាលនៃភូមិភាគសាន់ហ្វ្រាន់ស៊ីស្កូនៅម៉ូកូវីស (សាធារណៈរដ្ឋដូមីនិកាំង)**
**ឆ្លើយតបនឹងសំណើរ**
**ផ្ដល់ព្រះកាយព្រះគ្រីស្ដដល់ស្ត្រីមានកូនតែគ្មានស្វាមី** (Single Mother)

លិខិតលេខ៖ ៨០៣/២០២៣

ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

លោកអភិបាលជាទីគោរព!

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣កន្លងទៅ ក្រសួងគោលលិទ្ធិព្រះសហគមន៍បានទទួលសារអេឡិចត្រូនិករបស់លោកបង្ហាញពីក្ដីបារម្ភអំពីអ្នកម្ដាយដែលមានកូនដោយគ្មានស្វាមី (Single Mother) ដែលត្រូវបាន«ហាមមិនឲ្យទទួលព្រះកាយព្រះគ្រីស្ត មានអារម្មណ៍ភ័យខ្លាចចំពោះក្រុមគ្រហស្ថ និងអ្នកណែនាំព្រះសហគមន៍»។ សម្ដេចប៉ាប បានទទួលលិខិតជាច្រើនពីក្រុមគ្រហស្ថ អំពីរឿងតែមួយនេះ។ រឿងនេះត្រូវបានកត់សម្គាល់ថា នៅក្នុងប្រទេសមួយចំនួន ក្រុមលោកបូជាចារ្យនិងគ្រហស្ថ បានហាមប្រាមមាតាដែលមានកូនដោយមិនបានរៀបការមិនអាចទទួលអគ្គសញ្ញានានាបានឡើយ ហើយកូនរបស់នាងក៏មិនអាចទទួលអគ្គសញ្ញាជ្រមុជទឹកបានដែរ។

ថ្មីៗនេះ សម្ដេចប៉ាបបានរំលឹករឿងនេះថា «អភិបូជា គឺជាការឆ្លើយតបរបស់ព្រះជាម្ចាស់ ទៅនឹងសេចក្ដីស្រេកឃ្លានដ៏ខ្លាំងក្នុងជម្រៅចិត្តរបស់មនុស្ស ភាពស្រេកឃ្លានដែលចេញមកពីជីវិតពិតៗ ហើយសម្រាប់ព្រះកាយព្រះគ្រីស្ត ព្រះគ្រីស្តផ្ទាល់គង់នៅកណ្ដាលយើងរាល់គ្នា ដើម្បីចិញ្ចឹមផ្លូវវិញ្ញាណ លួងលោមដួងចិត្តនិងធ្វើដំណើររួមជាមួយយើង»។ ស្ត្រីដែលស្ថិតនៅក្នុងកាលៈទេសៈនេះ បានជ្រើសរើសជីវិតរួចទៅហើយ នាងបានធ្វើឲ្យជីវិតដ៏ស្អុគស្មាញកើតឡើងបាន ដោយសារជម្រើសនេះហើយ នាងគួរត្រូវបានលើកទឹកចិត្ត ដើម្បីទទួលបានការព្យាបាលនិងសម្រុះសម្រួលដោយអំណាចនៃអគ្គសញ្ញានានា។

ស្ថានភាពរបស់មាតាដែលមានកូនគ្មានស្វាមី និងការលំបាករបស់នាងនិងកូនរបស់នាងបានប្រឈមមុខនឹងការទទួលអគ្គសញ្ញាត្រូវបានបញ្ជាក់ដោយសម្ដេចប៉ាបម្ដងរួចហើយនៅពេលទ្រង់នៅជាកាឌីណាល់អគ្គអភិបាលនៃភូមិភាគប៊ូអេនូស អ៊ែរេស (Buenos Aires) យ៉ាងនេះថា៖ «មានលោកបូជាចារ្យមួយចំនួន មិនព្រមធ្វើពិធីជ្រមុជទឹកឲ្យកូនៗរបស់ស្ត្រីដែលគ្មានប្តី ពីព្រោះកូនរបស់នាងមិនបានកើតនៅក្នុងភាពដ៏វិសុទ្ធរបស់អាពាហ៍ពិពាហ៍។ ពួកគាត់ជាមនុស្សមានពុតត្បុតនាពេលបច្ចុប្បន្ននេះ។ ពួកគាត់បានបង្កើតឥទ្ធិពលបូជាចារ្យក្នុងព្រះសហគមន៍។ ពួកគាត់ បង្វែរប្រជាជនរបស់ព្រះជាម្ចាស់ចេញឆ្ងាយពីការសង្គ្រោះ។ ហើយស្ត្រីដ៏កំសត់នេះគួរតែត្រូវបានថ្វាយកូនរបស់ខ្លួនទៅកាន់ព្រះជាម្ចាស់ដែលបានចាត់វាឲ្យមកក្នុងលោកនេះ ប៉ុន្តែវាត្រូវធ្វើដំណើរបូជនីយេសក៍ក្នុងពិភពលោកពីព្រះសហគមន៍មួយទៅមួយ ដើម្បីសុំអគ្គសញ្ញាជ្រមុជទឹក។ ក្រោយមក សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ បានទទួលស្គាល់ភាពក្លាហានរបស់ស្ត្រីទាំងនេះ ដែលពពោះកំណើតកូន ដោយមានបន្ទូលថា៖ «ខ្ញុំដឹងថា វាមិនងាយស្រួលសម្រាប់នាងដែលជាម្ដាយមានកូនគ្មានស្វាមី។ ខ្ញុំដឹងថាមនុស្សមួយចំនួនពេលខ្លះអាចមើលងាយនាង។ ប៉ុន្តែ ខ្ញុំចង់ប្រាប់នាងថា៖ នាងជាស្ត្រីក្លាហាន ព្រោះនាងបានបង្កើតកូនស្រី២នាក់នេះក្នុងពិភពលោក។ នាងមានជម្រើសអាចសម្លាប់ពួកគេក្នុងផ្ទៃរបស់ខ្លួន ប៉ុន្តែនាងបានគោរពតម្លៃនៃជីវិត គឺឲ្យតម្លៃជីវិតដែលបានកើតក្នុងផ្ទៃរបស់នាង ហើយព្រះជាម្ចាស់នឹងផ្ដល់រង្វាន់ដល់នាងសម្រាប់រឿងនេះ ព្រះអង្គពិតជាផ្ដល់រង្វាន់ជាមិនខាន។ កុំខ្មាសអី សូមងើបមុខឡើងហើយសម្លឹងទៅមុខ៖ «ខ្ញុំមិនបានសម្លាប់កូនស្រីរបស់ខ្លួនឡើយ។ ខ្ញុំបានផ្ដល់ជីវិតឲ្យពួកគេក្នុងពិភពលោកនេះ។» ខ្ញុំសូមអបអរសាទរនាងម្ដងហើយម្ដងទៀត និងសូមព្រះជាម្ចាស់ប្រទានពរដល់នាង។»

ឆ្លងតាមរឿងនេះ កិច្ចការណែនាំថែទាំ(ដូចគង្វាល) គួរធ្វើដែរនៅក្នុងព្រះសហគមន៍ក្នុងភូមិ ត្រូវពន្យល់ដល់មនុស្សឲ្យយល់ថា ក្លាយជាម្ដាយដែលគ្មានស្វាមីមិនអាចបញ្ចៀសថា គាត់មិនអាចចូលរួមក្នុងអង្គព្រះគ្រីស្តបានទេ។ សម្រាប់គ្រីស្តបរិស័ទ អគ្គសញ្ញាលើកលែងទោសនៃអំពើបាបអនុញ្ញាតឲ្យបុគ្គលនោះអាចទទួលព្រះកាយព្រះគ្រីស្តបាន។ លើសពីនេះទៀត ព្រះសហគមន៍ គួរតែផ្ដល់តម្លៃដល់ភាពពិតដែលស្ត្រីមានកូនតែគ្មានស្វាមីហ៊ានស្វាគមន៍និងគាំពារអំណោយទាននៃជីវិតដែលពួកនាងកំពុងតែទទួលក្នុងផ្ទៃរបស់នាង ដោយលំបាកទាំងយប់ទាំងថ្ងៃដើម្បីចិញ្ចឹមកូនៗរបស់នាង។

ជាមួយគ្នានេះ ក៏មាន«ស្ថានការលំបាកខ្លះ» ដែលត្រូវការរគិតពិចារណានិងគាំទ្រតាមរបៀបគង្វាលព្រះសហគមន៍។ រឿងរ៉ាវអាចកើតឡើងបានដែរចំពោះម្ដាយខ្លះ ដែលបានជួបប្រទះនូវស្ថានការណ៍ដែលមិនចង់ជួប ហើយពេលខ្លះអាចជាការលក់ខ្លួនដើម្បីចិញ្ចឹមគ្រួសារ។ សហគមន៍គ្រីស្តបរិស័ទត្រូវបានត្រាស់ហៅឲ្យធ្វើអ្វីដែលអាចធ្វើទៅបានទាំងអស់ ដើម្បីជួយនាងឲ្យចាកចេញពីភាពប្រថុយប្រថានដ៏អាក្រក់នេះ ជាជាងវិនិច្ឆ័យនាងដោយរហ័សពេក។ ក្នុងហេតុផលនេះ «ព្រះសហគមន៍ដែលជាគង្វាល សូមឲ្យបងប្អូនរួមជំនឿដែលគោរពបម្រើព្រះបន្ទូលនិងរស់នៅតាមការប្រៀនប្រដៅរបស់ព្រះសហគមន៍ ត្រូវតែជួយពួកនាង និងប្រព្រឹត្តចំពោះជនទន់ខ្សោយដោយសេចក្ដីមេត្តា ចៀសវាងការធ្វើឲ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរ ឬវិនិច្ឆ័យដោយឃោឃៅហួសហេតុនិងដោយប្រញាប់ប្រញាល់ពេក»។

ជាញឹកញាប់ ពេលអធិប្បាយលើអត្ថបទព្រះគម្ពីរអំពីស្ត្រីម្នាក់ប្រព្រឹត្តសហាយស្មន់ (យហ៨,១-១១) ឃ្លាចុងក្រោយបានបញ្ជាក់ថា «ខ្ញុំមិនដាក់ទោសនាងទេ។ ពិតណាស់ព្រះយេស៊ូអញ្ជើញយើងដើម្បីកែប្រែជីវិតរបស់យើង ដើម្បីឆ្លើយតបចំពោះគោលបំណងរបស់ព្រះជាម្ចាស់តាមរយៈជំនឿ និងដើម្បីឲ្យយើងរស់នៅក្នុងកិត្តិយសដ៏ប្រសើរឧត្ដម។ ទោះបីជាយ៉ាងណាក៏ដោយ ឃ្លានេះមិនមែនជាសារសំខាន់ឆ្លុះបញ្ចាំងនៃដំណឹងល្អនេះទេ ដែលគ្រាន់តែជាការអញ្ជើញឱ្យទទួលស្គាល់ថាគ្មាននរណាម្នាក់អាចចោលដុំថ្មដំបូងបានឡើយ។ ចំពោះហេតុផលនេះ សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ សំដៅទៅលើម្ដាយដែលត្រូវចិញ្ចឹមកូនតែម្នាក់ឯង ហើយឃ្លាគម្ពីរនេះរំឭកយើងថា «នៅក្នុងស្ថានភាពបែបនេះ ព្រះសហគមន៍ត្រូវតែរិះគិតពិចារណា ដោយយោគយល់ សម្រាលទុក្ខព្រួយ និងទទួលស្គាល់ ជាជាងដាក់សម្ពាធដោយច្បាប់ ដែលនាំឲ្យមនុស្សមានអារម្មណ៍ដូចជាអ្នកទោសនិងឯកោ ដោយសារភាពជាម្ដាយពិតប្រាកដ(របស់ព្រះសហគមន៍) ត្រូវបានត្រាស់ហៅឲ្យបង្ហាញពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

ជាទីបញ្ចប់នេះ ជារឿងចាំបាច់ណាស់ដែលត្រូវបញ្ជាក់បន្ទូលរបស់សម្ដេចប៉ាបជាថ្មីនៅក្នុងសន្និបាតព្រះសហគមន៍ (Synod)។ ទ្រង់បានសង្កត់ធ្ងន់លើភាពជាស្ត្រីនិងមុខមាត់របស់ព្រះសហគមន៍ ហើយបានបរិហារពី « អាកប្បកិរិយារបស់អ្នកកាន់អំណាច និងការផ្ដាច់ការ » របស់អ្នកបម្រើក្នុងព្រះសហគមន៍ដែល «ធ្វើហួសឆ្ងាយអំពីមុខងារនៃការបម្រើរបស់ពួកគាត់ ហើយបានធ្វើបាបប្រជារាស្ត្ររបស់ព្រះជាម្ចាស់»។ ហេតុនេះ អ្វីៗវាអាស្រ័យលើលោក ដើម្បីធានាថាអាកប្បកិរិយាប្រភេទនេះមិនកើតឡើងនៅក្នុងព្រះសហគមន៍ក្នុងតំបន់របស់លោកនោះទេ។

ជាមួយកិច្ចសន្ទនាខាងលើនេះ ខ្ញុំសូមយកឱកាសនេះ ជូនពរដល់លោកអភិបាលទទួលបានអំណរសប្បាយក្នុងបុណ្យព្រះយេស៊ូប្រសូត។ សូមទទួលសេចក្ដីគោរពនិងរាប់អានរបស់ខ្ញុំក្នុងនាមជាបងប្អូន។

ក្នុងអង្គព្រះគ្រីស្ត
លោកកាឌីណាល់ វីកទ័រ ម៉ានូអែល ហ្វេរណាន់ដេស
អធិបតីក្រសួងសម្រាប់គោលលិទ្ធិនៃជំនឿ
(Prefect of DICASTERIUM PRO DOCTRINA FIDEI)





# គ្រីស្តបរិស័ទក្នុងភូមិភាគបាត់ដំបងរិះគិតពី «Synodal Church»

*អត្ថបទ៖ កែវ កញ្ញា*



ក្នុងកិច្ចប្រជុំប៉ាស្ទ៉រ៉ាល់របស់ព្រះសគមន៍ភូមិភាគបាត់ដំបង បានលើកយកសន្និបាតព្រះសហមន៍សកល Synodal Church មករិះគិតរួមគ្នា ដើម្បីឲ្យគ្រីស្តបរិស័ទ និងអ្នកដឹកនាំព្រះសហគមន៍បានយល់កាន់តែច្បាស់អំពីអ្វីទៅជាSynodal Church។

Synodal Church ត្រូវបានរៀបចំឡើងដោយសម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ ដើម្បីរិះគិតអំពីរបៀបធ្វើដំណើររបស់ព្រះសហគមន៍នៅក្នុងពិភពលោកនេះ ដោយផ្ដោតសំខាន់លើដំណើរជាមួយគ្នាជាធ្លុងតែមួយក្នុងព្រះសហគមន៍ និងរួមគ្នាប្រកាសដំណឹងល្អ។

កិច្ចប្រជុំនេះ មានគ្រីស្តបរិស័ទ៧០នាក់មកពីព្រះសហគមន៍នានា ក្នុងភូមិភាគបាត់ដំបងចូលរួម និងរិះគិតក្រោមប្រធានបទ «ការដឹកនាំប្រកបដោយព្រះវិញ្ញាណដ៏វិសុទ្ធ» ដែលធ្វើនៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ (ពេទ្យឃាយជី) ស្ថិតនៅ ភូមិរំចេក១ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានរយៈពេល៣ថ្ងៃ ពីថ្ងៃទី៧-៩ ខែវិច្ឆិកា ឆ្នាំ២០២៣។





នៅថ្ងៃបើកកម្មវិធីលោកអភិបាល អេនរីគេ ហ្វីការេដូអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងមានប្រសាសន៍ថា «ប្រជុំប៉ាស្ទ៉រ៉ាល់នេះ គឺជាពេលវេលាដែលយើងត្រូវអធិដ្ឋាន ស្ដាប់គ្នា ជួបគ្នាសួរសុខទុក្ខ មិនមែនជាពេលសម្រេចធ្វើអ្វីមួយឡើយ។» លោកបានលើកឡើងទៀតថា ក្នុងរយៈពេល៣ថ្ងៃនេះ ចំណុចសំខាន់គឺឲ្យគ្រីស្តបរិស័ទម្នាក់ៗត្រូវចូលរួមនិងទទួលខុសត្រូវលើព្រះសហគមន៍ផ្ទាល់ខ្លួន។

ក្នុងកិច្ចប្រជុំនេះ មានរៀបចំជាសិក្ខាសាលាតូចៗ ដែលមានវាគ្មិនចំនួន៣រូប ធ្វើបទបង្ហាញនិងផ្ដល់គន្លឹះសំខាន់ៗ ដើម្បីឲ្យគ្រីស្តបរិស័ទយល់ដឹងបន្ថែម អំពីអ្វីទៅជាសន្និបាតព្រះសហគមន៍សកលដែលបាននិងកំពុងរៀបចំ នៅទីក្រុងរ៉ូមនិងតាមបណ្ដាទ្វីបទាំង៥ដែលព្រះសហគមន៍កំពុងមានវត្តមាន។



បណ្ឌិត ខេង គ្រីស្ទីណា ជាវាគ្មិនមកពីប្រទេសសិង្ហបុរី បានណែនាំអង្គសិក្ខាសាលាឲ្យយល់អំពីមូលហេតុ និងដំណើរការផ្សេងៗដែលព្រះសហគមន៍ធ្វើសន្និបាតព្រះសហគមន៍សកលនេះឡើង។

បណ្ឌិតទេវវិទ្យារូបនេះឲ្យដឹងថា ៖ «ព្រះសហគមន៍មានចរនាសម្ព័ន្ធជាពីរ៉ាមីត នាំឲ្យមានគម្លាតមួយរវាងអ្នកខាងលើនិងអ្នកខាងក្រោម ដូច្នេះព្រះសហគមន៍បានរិះគិតរកពាក្យមួយ គឺSynodal ដើម្បីឲ្យយើងដឹងអំពីអ្វីដែលព្រះជាម្ចាស់ត្រាស់ហៅយើងចូលរួមក្នុងព្រះសហគមន៍ ហើយយើងត្រូវមានទំនាក់ទំនងគ្នានិងស្គាល់ដូចបងប្អូន និងមិត្តភក្តិ»។

គាត់បញ្ជាក់ថា ៖ «នេះជាផ្លូវថ្មីដែលយើងធ្វើដំណើររួមគ្នា»។

សន្និបាតព្រះសហគមន៍សកលបានចាប់ផ្ដើមឡើងតាំងពីឆ្នាំ២០២១-២០២៤។ កាលពីឆ្នាំ២០២១ ព្រះសហគមន៍នៅគ្រប់តំបន់ក្នុងពិភពលោកបានរិះគិត លើសំណួរចំនួន៣ គឺតើយើងគួរធ្វើដំណើររួមគ្នាយ៉ាងណា? តើព្រះវិញ្ញាណដឹកនាំឲ្យធ្វើអ្វី? តើការធ្វើដំណើរជាធ្លុងតែមួយជួយប្រកាសដំណឹងល្អដូចម្ដេច? ហើយរាល់ចម្លើយទាំងអស់ត្រូវបានបញ្ជូនទៅកាន់ទីក្រុងរ៉ូមដើម្បីទុកជាឯកសារនិងរិះគិត។



ក្នុងខែតុលាឆ្នាំ២០២៣កន្លងទៅ លោកអភិបាល បព្វជិត-ជិតា និងគ្រហស្ថមួយចំនួនត្រូវបានអញ្ជើញទៅកាន់ទីក្រុងរ៉ូមដើម្បីស្ដាប់និងចែករំលែកពិសោធន៍រួមជាមួយគ្នារយៈពេលមួយខែពេញ។ ក្នុងនោះក៏មានលោកអភិបាលអេនរីគេ ហ្វីការេដូចូលរួមជាតំណាងលោកអភិបាលឡាវ-កម្ពុជា។

ក្នុងប្រជុំប៉ាស្ទ៉រ៉ាល់នេះ វាគ្មិនទាំងអស់បានណែនាំឲ្យសិក្ខាកាមមានបទពិសោធនៃការស្ដាប់ និងចែករំលែកតាមរបៀបដែលព្រះសហគមន៍សកលបានធ្វើនៅទីក្រុងរ៉ូម ដើម្បីយកទៅអនុវត្តក្នុងព្រះសហគមន៍ផ្ទាល់ខ្លួន។ ក្នុងនោះផ្ដោតសំខាន់លើរបៀបនៃការអធិដ្ឋាន របៀបនៃការចូលរួម ទំនាក់ទំនង ស្ដាប់និងផ្ដល់យោបល់ និងរបៀបស្រឡាញ់ដែលគ្រីស្តបរិស័ទម្នាក់ៗអាចចូលរួមជាមួយគ្នា។

តាមប្រសាសន៍របស់ដូនជី ចារ៉ាថានីត សុដាធីប ជាក្រុមគ្រួសារអ្នកបម្រើសេចក្ដីស្រលាញ់ដ៏និមលរបស់ព្រះនាងម៉ារី បានឱ្យដឹងថា ក្រោយពេលចូលរួមសិក្ខាសាលានេះ គាត់អាចយល់ច្បាស់អំពីSynodal ជាអ្វី។

ដូនជីយល់ឃើញថា ព្រះសហគមន៍បច្ចុប្បន្នកំពុងដើរទៅមុខបន្តិចម្ដងៗតាមរបៀបSynodalនេះ និងធ្វើដំណើរបានល្អហើយទទួលជោគជ័យ។

លោក ឆេង ម៉ាប់ អ្នកសម្របសម្រួលកម្មវិធីបំណិនជីវិតសម្រាប់យុវជននិងគ្រួសារ ភូមិភាគបាត់ដំបង បានយល់ថា «កិច្ចប្រជុំជាការអធិដ្ឋាន ដោយមិនប្រើគំនិតខ្លួនឯងទេ ដោយឲ្យព្រះវិញ្ញាណណែនាំយើងវិញ។ ហើយអ្វីដែលមកពីព្រះវិញ្ញាណ វាងាយស្រួលទទួល និងផ្ដល់ឲ្យដែរ»។

បន្ទាប់ពីកិច្ចប្រជុំប៉ាស្ទ៉រ៉ាល់នេះ លោកនឹងយករបៀបដែលបានរៀន ទៅបង្កើតកិច្ចប្រជុំជាក់លាក់សម្រាប់កម្មវិធីរបស់លោកផ្ទាល់ ដោយស្ដាប់អំពីអារម្មណ៍និងតម្រូវការរបស់គ្នាទៅវិញទៅមក។

«នេះខ្ញុំគិតថា ជាអ្វីដែលនឹងជួយឲ្យព្រះសហគមន៍យើងរីកចម្រើនដូចមានឈ្មោះថាSynodality ដោយយើងរួមដំណើរជាមួយគ្នា រួមសុខទុក្ខជាមួយគ្នា ដើម្បីអភិវឌ្ឍព្រះសហគមន៍របស់យើង»។ លោក ឆេង ម៉ាប់ បញ្ជាក់។

ជាមួយគ្នានេះកញ្ញា ហុងវណ្ណី ជាគ្រូអប់រំជំនឿបាននិយាយថា ចំណុចសំខាន់សម្រាប់Synodal គឺការរួបរួម ក្រោមការបំភ្លឺរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ វណ្ណីសង្ឃឹមថា សន្និបាតនឹងជួយដាស់តឿនយើងឲ្យយើងភ្ញាក់រឭកអំពីរបៀបរស់នៅរបស់ព្រះសហគមន៍តាំងពីសម័យគ្រីស្តទូតមកដល់បច្ចុប្បន្នលើកិច្ចសហប្រតិបត្តិការនិងការកសាងរួមគ្នាដើម្បីឲ្យព្រះសហគមន៍រីកចម្រើនទៅមុខ៕

# សង្ខេបព្រឹត្តិការណ៍៖ ភូមិភាគភ្នំពេញ- ភូមិភាគកំពង់ចាម-ភូមិភាគបាត់ដំបង

## សិស្ស ៦០នាក់ នៃសាលាបឋមសិក្សា ពញាក្រែកទទួលបានសម្ភារសិក្សា



*សិស្សានុសិស្ស នៃសាលាបឋមសិក្សាពញាក្រែក ក្នុងខណ្ឌឫស្សីកែវ។*

សិស្សានុសិស្ស មកពីសាលាបឋមសិក្សាពញាក្រែក ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រមាណជាជាង ៦០០ នាក់ បានទទួលសម្ភារសិក្សាពីព្រះសហគមន៍សន្តយ៉ូសែប កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣។

ពិធីផ្តល់សម្ភារសិក្សាជូនដល់សិស្សានុសិស្សនេះ បានធ្វើឡើងក្រោមអធិបតីភាពមន្ត្រីខណ្ឌឫស្សីកែវ លោកបូជាចារ្យ រឿង ឆ័ត្រសិរី អ្នកទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងជើង និងបងស្រី ឡាវ៉ាន់ ដែលជាតំណាងព្រះសហគមន៍សន្តយ៉ូសែប។

សូមបញ្ជាក់ដែរថា សាលាបឋមសិក្សាពញាក្រែក ស្ថាបនាឡើងនៅឆ្នាំ១៩៦០ ដែលលោកអភិបាល ឆ្មារ សាឡាស់ បានរៀនសូត្រនៅទីនេះដែរ កាលពីកុមារភាព៕



*លោកឪពុក ឆាល់ ត្រូវបានតែងតាំងជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពតាកែវ។*

## លោកឪពុក ឆាល់ តែងតាំងជាបូជាចារ្យ ទទួលខុសត្រូវមណ្ឌលសកម្មភាពតាកែវ

លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ អភិបាលភូមិភាគភ្នំពេញ បានប្រកាសតែងតាំង លោកឪពុក Charles Ekuwam Lechipan ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពតាកែវ ក្នុងភូមិភាគភ្នំពេញជាផ្លូវការ នាព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៣ នៅព្រះសហគមន៍សន្តីម៉ារី ញញឹម ចំការទៀង។

ជាមួយគ្នានោះដែរ មណ្ឌលសកម្មភាពតាកែវ ដែលមានបេក្ខជនទទួលអគ្គសញ្ញាលាបថ្ងាស ៤០នាក់ ផងដែរ។ មណ្ឌលសកម្មភាពតាកែវ មានព្រះសហគមន៍ចំនួន ៨កន្លែង និងមានលោកបូជាចារ្យចំនួន ៣អង្គ រួមមានលោកឪពុក ឆាល់ ជាប្រធាន មានលោកឪពុក ចន និងលោកឪពុក កាន់ ជាបូជាចារ្យជំនួយ៕

## បុណ្យឆ្លងព្រះវិហារ«ព្រះនាងម៉ារី ជាមាតានៃព្រះសហគមន៍»



*ពិធីបុណ្យឆ្លងព្រះវិហារ«ព្រះនាងម៉ារីជាមាតានៃព្រះសហគមន៍»។*

នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ បានរៀបចំធ្វើពិធីបុណ្យឆ្លងព្រះវិហារ «ព្រះនាងម៉ារីជាមាតានៃព្រះសហគមន៍» នៅព្រះសហគមន៍តាអំ ក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

ព្រះសហគមន៍កាតូលិកតាអំ កើតឡើងនៅឆ្នាំ១៨៨១ ព្រះវិហារនេះត្រូវបានកសាងឡើងនៅចន្លោះឆ្នាំ១៩១០-ឆ្នាំ១៩២០ ហើយត្រូវបានបំផ្លាញក្នុងអំឡុងពេលសង្គ្រាមរវាងឆ្នាំ១៩៧០ ដល់១៩៧៥។ នៅឆ្នាំ២០០៤ ព្រះសហគមន៍បានជួសជុលព្រះវិហារនេះជាបណ្តោះអាសន្ន ហើយបានជួសជុលឡើងវិញរួចរាល់នៅឆ្នាំ២០២១៕



*សិក្ខាសាលា គ្រូអប់រំជំនឿ អន្តរភូមិភាគ ដែលមានភូមិភាគភ្នំពេញ,កំពង់ចាម និងភូមិភាគបាត់ដំបងឆ្នាំ២០២៣ ។*

## សិក្ខាសាលា គ្រូអប់រំជំនឿ អន្តរភូមិភាគ

សិក្ខាសាលា គ្រូអប់រំជំនឿ អន្តរភូមិភាគ ដែលមានភូមិភាគភ្នំពេញ,កំពង់ចាម និងភូមិភាគបាត់ដំបងឆ្នាំ២០២៣ បានធ្វើឡើងក្រោមប្រធានបទ «ធម៌ប្រកាសជំនឿ» ដែលបានប្រារព្ធកាលពីថ្ងៃទី៣១ ខែតុលា ដល់ទី២ ខែវិច្ឆិកា ឆ្នាំ២០២៣។

ក្នុងថ្ងៃទី១ នេះសិក្ខាកាមទាំងបានសិក្សាស្វែងរកយល់អំពី៖ (១) សភាពរបស់ព្រះយេស៊ូគ្រីស្ត៖ សភាពជាព្រះជាម្ចាស់របស់ព្រះយេស៊ូ និងសភាពជាមនុស្សរបស់ព្រះយេស៊ូ។ ប្រធានបទនេះ ណែនាំដោយ លោ កបូជាចារ្យ ជួរ ដាម៉ូ។ (២) អំពីជំនឿ និងប្រាជ្ញា ដែលណែនាំដោយលោក កាន់ ប៊ុយ និងបញ្ចប់ថ្ងៃទី១ ដោយពិធីអរព្រះគុណ និង អធិដ្ឋាន តេហ្សេ។

ថ្ងៃទី២ សិក្ខាកាមក៏បន្តសិក្សាឈ្វេងយល់បន្ថែមទៀតនូវប្រធានបទ ដែលណែនាំដោយលោកអភិបាល សិលា សួន ហង្សលី និងលោកបូជាចារ្យ ហ្វ្រង់កូ ទាក់ទងនឹងប្រធានបទពីធម៌ប្រកាសជំនឿ និងពីព្រះត្រៃឯក ណែនាំដោយលោកបូជាចារ្យ ហ្វ្រង់ស័រ៕





សង្ខេបព្រឹត្តិការណ៍៖ ភូមិភាគភ្នំពេញ- ភូមិភាគកំពង់ចាម-ភូមិភាគបាត់ដំបង

## ពិធីបិទវគ្គឆ្នាំសិក្សា២០២២-២០២៣ សាលាមត្តេយ្យកុមាររីករាយនៃព្រះសហគមន៍ កាតូលិកសន្តបេណេឌិកតូព្រៃវែង

សិស្ស សាលាមត្តេយ្យកុមាររីករាយនៃព្រះសហគមន៍កាតូលិកសន្តបេណេឌិកតូព្រៃវែង ប្រមាណជា៧០នាក់ បានរៀបចំកម្មវិធីបិទវគ្គឆ្នាំសិក្សា២០២២-២០២៣ ដោយមានការចូលរួមពីសំណាក់លោកអភិបាល សិលា សួន ហង្សលី នៃព្រះសហគមន៍កំពង់ចាម លោកបូជាចារ្យ សិលា បងស្រី អាង សង្វាត បងស្រី កញ្ញា ព្រមទាំងឪពុកម្តាយ អាណាព្យាបាលកុមារា កុមារី យ៉ាងសប្បាយរីករាយ។

កម្មវិធីបិទវគ្គឆ្នាំសិក្សា២០២២-២០២៣ បានធ្វើឡើងកាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣។ ក្នុងការបិទវគ្គឆ្នាំសិក្សានេះ លោកអភិបាលសិលា សួន ហង្សលី បានណែនាំឱ្យមានការធ្វើអនាម័យខ្លួនប្រាណ អនាម័យបរិស្ថាន ដែលជាសីលធម៌ដ៏ល្អសម្រាប់មនុស្សនៅក្នុងសង្គមជាតិ៕



*សិស្សានុសិស្សនៅវិធីបិទវគ្គឆ្នាំសិក្សា២០២២-២០២៣។*

## សម្ពោធ សាលាបឋមសិក្សានៃសន្តិភាព និងផ្ទះក្រុមបងស្រីឧសុលីន

សាលាបឋមសិក្សានៃសន្តិភាព និងផ្ទះក្រុមបងស្រីឧសុលីន ខេត្តបាត់ដំបង ត្រូវបានសម្ពោធនិងប្រសិទ្ធពរ ដែលស្ថិតនៅក្នុងភូមិប្រាបវាល ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣។ កម្មវិធីនេះ មានការចូលរួមដោយលោក នន់ គីមនី អភិបាលរងស្រុកសង្កែ តំណាងខាងមន្ទីរអប់រំ យុវជននិងកីឡា លោកបូជាចារ្យ បុងបុង ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ប្រាបវាល និងជាតំណាងពេញសិទ្ធរបស់លោកអភិបាលនិងក្រុមបងស្រីឧសុលីន និងលោកបូជាចារ្យ បងប្រុស បងស្រី លោក លីន ឡា ជានាយកសាលាបឋមសិក្សា ព្រមទាំងអាណាព្យាបាល មាតា បិតាសិស្ស និងសិស្សានុសិស្ស៕



*ពិធីសម្ពោធ សាលាបឋមសិក្សានៃសន្តិភាព និងផ្ទះក្រុមបងស្រីឧសុលីន ស្ថិតនៅក្នុងខេត្តបាត់ដំបង។*

## កម្មវិធីបោះជំរំបរិស្ថាន នៅសហគមន៍ តំបន់ការពារធម្មជាតិសង្ឃរុក្ខាវ័ន



*កម្មវិធីបោះជំរុំបរិស្ថាន នៅសហគមន៍តំបន់ការពារធម្មជាតិសង្ឃរុក្ខាវ័ន។*

អង្គការ Jesuit Service Cambodia សហការជាមួយនិងសហគមន៍ភូមិភាគបាត់ដំបង បានរៀបចំកម្មវិធីបោះជំរំបរិស្ថាន (ECOLOGY PROGRAM) នៅសហគមន៍តំបន់ការពារធម្មជាតិសង្ឃរុក្ខាវ័ន ដែលស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ។

កម្មវិធីនេះរៀបចំឡើងដោយអង្គការ Jesuit Service Cambodia សហការជាមួយលោកបូជាចារ្យ ព្រីយ៉ាឌី ហ្រ្គេហ្គោរីអូស ជាអ្នកទទួលខុសត្រូវផ្នែកបរិស្ថាននៅក្នុងព្រះសហគមន៍ភូមិភាគបាត់ដំបង ដោយមានការចូលរួមពីយុវជនមកពីព្រះសហគមន៍បាត់ដំបង ប៉ោយប៉ែត និគមស្វាយស៊ីសុផុន ឧត្តរមានជ័យ តាហែន និងមណ្ឌលទេពអ៊ីម ប្រមាណជាង៥០នាក់។ ការបោះជំរុំនេះចាប់ពីថ្ងៃទី២៣-២៦ ខែវិច្ឆិកា ឆ្នាំ២០២៣៕

## សិក្ខាសាលា ពន្លកថ្មីលើកទី២

សិក្ខាសាលាពន្លកថ្មីលើកទី២បានប្រារព្ធឡើង កាលពីថ្ងៃទី២៤ ដល់ទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅមណ្ឌលប្រកាសដំណឹងល្អកាឡូស បូរូមេ នៃភូមិភាគបាត់ដំបង។

កម្មវិធីនេះ ត្រូវបានណែនាំដោយគណៈកម្មការព្រះគម្ពីរភូមិភាគបាត់ដំបង ដោយមានលោកបូជាចារ្យទម្លាប់ សុផល ជាប្រធាន។ កម្មវិធីនេះមានអ្នកចូលរួមប្រមាណជាង ៣៩នាក់ ដែលមកពីព្រះសហគមន៍សៀមរាបប៉ោយប៉ែតខ្នាចរមាស តាហែន និងបាត់ដំបង៕



*សិក្ខាសាលាពន្លកថ្មី លើកទី២ ដែលកម្មវិធីនេះ បានណែនាំដោយគណៈកម្មការព្រះគម្ពីរភូមិភាគបាត់ដំបង ដោយមានលោកឪពុកសិលា ទម្លាប់ សិផល ជាប្រធាន។*

# សម្តេចប៉ាប ស្នើសុំឱ្យមេដឹកនាំសាសនា យកចិត្តទុកដាក់ការប្រែប្រួលអាកាសធាតុ




*អត្ថបទ៖ អរិយបុត្រ*

មេដឹកនាំសាសនានានាត្រូវបានជំរុញនិងលើកទឹកចិត្តឲ្យយកចិត្តទុកដាក់ជាពិសេសនៅលើបញ្ហានៃបម្រែបម្រួលអាកាសធាតុ ដែលកំពុងតែគំរាមកំហែងជីវិតមនុស្ស សត្វ និងរុក្ខជាតិ នៅពេលបច្ចុប្បន្ននេះ។

វ៉ាទីកង់ញូវបានរាយការណ៍ថា នេះគឺជាសាររបស់សម្តេចប៉ាបតាមរយៈវីដេអូ ដែលទ្រង់បានមានបន្ទូលទៅកាន់កម្មវិធីនៃការសម្ពោធព្រះពន្លានៃជំនឿ នាអង្គសន្និសីទថ្នាក់ខ្ពស់ស្តីអំពីបម្រែបម្រួលអាកាសធាតុដែលរៀបចំនៅទីក្រុង ឌូបៃ កាលពីពេលថ្មីៗនេះ។

នៅក្នុងឱកាសនោះសម្តេចប៉ាបបានជំរុញឱ្យគ្រប់មេដឹកនាំសាសនា ធ្វើការជាមួយគ្នាដោ យសន្តិភាព និង យោគយល់គ្នាធ្វើយ៉ាងណា ដើម្បីអោយពិភពលោក លើកកំពស់ការយកចិត្តទុកដាក់ចំពោះការការពារនិងបង្ការបញ្ហាផ្សេងៗដែលគំរាមកំហែងដោយបម្រែបម្រួល អាកាសធាតុ។

សម្តេចបានបានជំរុញឱ្យមានការចងក្រងគ្នាជាក្រុម ឬជាសម្ព័ន្ធ ដើម្បីរិះគិតអំពីការច្នៃប្រឌិត និងដាក់ចេញនូវកម្មវិធី ដែលមានអត្ថប្រយោជន៍ប្រកបដោយឆន្ទៈរួមគ្នាដោះស្រាយបញ្ហា អាកាសធាតុ៕

# លោកអូលីវីយេ ឱ្យគ្រីស្តបរិស័ទកាយអំពើបាបចេញពីខ្លួន



*អត្ថបទ៖ កែវ កញ្ញា*

លោក អូលីវីយេ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានសុំឱ្យគ្រីស្តបរិស័ទរៀបចំខ្លួន ដូចការដ្ឋានផ្លូវថ្នល់ ដែលត្រូវកាយដីមិនល្អចេញ ហើយត្រូវបំពេញដោយថ្មគ្រឹះ ក្នុងនោះគឺគ្រីស្តបរិស័ទត្រូវកាយចេញនូវអំពើបាប និងទម្លាប់អាក្រក់ក្នុងខ្លួន និងចាក់បញ្ចូលនូវព្រះបន្ទូលព្រះជាម្ចាស់ និងអគ្គសញ្ញាផ្សេងៗចូលក្នុងដួងចិត្តជំនួសវិញ។

លោកអភិបាលថ្លែងដូចនេះ ក្នុងធម្មទេសនានាថ្ងៃទី១០ ខែធ្នូ នៅព្រះវិហារ សន្តអូគូស្តាំង នៃខេត្តកំពត ដែលមានគ្រីស្តបរិស័ទប្រមាណ១០០នាក់មកពីព្រះសហគមន៍ចំនួន៥ ដែលស្ថិតក្នុងមណ្ឌលសកម្មភាពកំពត-កែប និងពីសាលាដុនបូស្កូចូលរួម លោកអូលីវីយេ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានប្រសាសន៍ថា ព្រះជាម្ចាស់ឱ្យយើងរៀបចំផ្លូវនៃជីវិតដើម្បីទទួលព្រះជាម្ចាស់។

លោកបានមានប្រសាសន៍ថា ៖ «ក្នុងរដូវរង់ចាំនេះ យើងត្រូវឱ្យព្រះវិញ្ញាណនាំយើង ឱ្យស្គាល់អំណោយទាន៧របស់ព្រះជាម្ចាស់ដែលប្រៀបដូចជាទឹកដែលស្រោចលើផ្លូវកុំឱ្យហុយនិងមើលឃើញផ្លូវច្បាស់លាស់»។ ក្នុងឱកាសនោះដែរ លោកអភិបាល ក៏បានឱ្យគ្រីស្តបរិស័ទកែប្រែចិត្តគំនិត ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានទំនាក់ទំនងជាមួយព្រះយេស៊ូ និង ត្រូវបេះតស៊ូ ដាក់ខ្លួន និងស្រឡាញ់បងប្អូនឯទៀតៗ។

លោកអភិបាលបន្តថា «យើងត្រូវទំនាក់ទំនង ជាមួយព្រះយេស៊ូ ដើម្បីឱ្យយើងមានគ្រឹះរឹងមាំក្នុងជីវិតរបស់យើង»។

ក្នុងកម្មវិធីថ្ងៃនោះដែរ លោកអភិបាលអូលីវីយេ បានធ្វើអគ្គសញ្ញាលាបថ្វាសជូនដល់បេក្ខជនចំនួន៨រូបផងដែរ។

អគ្គសញ្ញាលាបថ្វាសធ្វើឲ្យព្រះអំណោយទានរបស់ព្រះជាម្ចាស់បានពេញលក្ខណៈ ដោយផ្តល់នូវព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីឲ្យគ្រីស្តបរិស័ទចាក់ឫសយ៉ាងជ្រៅក្នុងពូជពង្សជាបុត្រធីតារបស់ព្រះជាម្ចាស់ ហើយរួមជាមួយព្រះគ្រីស្តយ៉ាងស្និទ្ធស្នាល និងចូលរួមក្នុងបេសកកម្មរបស់ព្រះសហគមន៍ច្រើនជាងមុន ផ្តល់សក្ខីភាពអំពីជំនឿតាមរយៈពាក្យសម្តីនិងកិច្ចការនានា (គោល១៣១៦)។ អគ្គសញ្ញានេះអាចទទួលតែម្តងប៉ុណ្ណោះក្នុងមួយជីវិត៕

## គ្រីស្តបរិស័ទ ៣០ លាននាក់ នឹងធ្វើធម្មយាត្រានៅទីក្រុងរ៉ូម

*អត្ថបទ៖ អរិយបុត្រ*

គ្រីស្តបរិស័ទប្រមាណជា ៣០ លាននាក់ ត្រូវបានគេរំពឹងថា នឹងមកចូលរួមកម្មវិធីធម្មយាត្រានៅទីក្រុងរ៉ូម ខណៈពេលដែលសន្តអាសនៈគ្រោងនឹងរៀបចំពិធីដើម្បីឆ្លងឆ្នាំអំណរសប្បាយ២០២៥។

តាមសេចក្តីរាយការណ៍របស់វ៉ាទីកង់ញូវបានឲ្យដឹងថា ដំណើរការៀបចំកម្មវិធីអបអរឆ្នាំនៃអំណរសប្បាយ២០២៥ កំពុងតែត្រៀម ដោយនៅក្នុងនោះការិយាល័យព័ត៌មានសន្តអាសនៈ ក៏កំពុងតែចូលរួមដំណើរការនេះផងដែរ។

ក្រៅពីកម្មវិធីអំណរសប្បាយនេះ អ្នកជំនាញរបស់សន្តអាសនៈក៏កំពុងតែត្រៀម និងសិក្សានូវគម្រោងសំខាន់ៗចំនួនពីរ ដែលគម្រោងទាំងនេះ គឺមានគោលបំណងជួយជនភៀសខ្លួន និង មនុស្សដែលងាយរងគ្រោះនានា រួមទាំងអ្នកទោសផងដែរ ។

ពាក់ព័ន្ធនឹងគម្រោងនេះ លោកកាឌីណាល់ ម្ញ៉ូ ហ្គាំបេតទី អ្នកទទួលខុសត្រូវកម្មវិធីនេះ បានមានប្រសាសន៍នៅក្នុងសន្និសីទកាសែតមួយថា កម្មវិធីធម្មយាត្រា និងឆ្នាំអំណរសប្បាយ ដែលនឹងរៀបចំរួមគ្នា រួមជាមួយនឹងការដាក់ចេញនូវគម្រោងទាំងពីរ។

សូមរំលឹកថា ឆ្នាំនៃអំណរសប្បាយបែបនេះ គឺត្រូវបានរៀបចំនៅរៀងរាល់៥០ ឆ្នាំម្តង ដើម្បីរំលឹកដល់ការចងចាំដែលជនជាតិជ្វីប បានរត់គេចចេញពីទាសការនៅក្នុងប្រទេសអេស៊ីប។

តាំងពីបុរាណមក ឆ្នាំនៃអំណរសប្បាយនេះ គឺគេរំលឹកដល់ការដែលទាសករទទួលឥស្សរភាព និងលើកលែងបំណុលហើយថែមទាំងមានការចែកចាយដីដើម្បីបង្កបង្កើនផលថែមទៀតផង៕

## យុវជនប្រមាណ១០០នាក់ ចូលរួមឈ្វេងយល់ អំពីការត្រាស់ហៅ

*អត្ថបទ៖ ចាន់ ម៉ានុត*

យុវជនប្រមាណជា១០០នាក់ មកពី៩មណ្ឌលសកម្មភាពក្នុងភូមិភាគភ្នំពេញ បានចូលរួមកម្មវិធីបោះជំរុំសម្រាប់ការត្រាស់ហៅដែលរៀបចំឡើងដោយ គណៈកម្មការដើម្បីការត្រាស់ហៅ ក្រោមប្រធានបទ «ពេលវេលានៅជាមួយព្រះយេស៊ូ» នៅរមណីយដ្ឋាន ឋានសួគ៌ធម្មជាតិភ្នំវល្លិ៍ ស្ថិតនៅក្នុងខេត្តកែប។

កម្មវិធីនេះធ្វើឡើងកាលពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយមានការចូលរួមដោយលោកអភិបាល អូលីវីយេ ជ្មីតហាស្លេអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកបូជាចារ្យជាច្រើនអង្គ ក្រុមបព្វជិត-ជិតា ជាច្រើនទៀត។

លោកបូជាចារ្យ វី សំណាង គណៈកម្មការកម្មវិធីការត្រាស់ហៅនេះ បានឱ្យដឹងថា ទិសដៅសំខាន់នៃកិច្ចបោះជំរំនេះ គឺជួយតម្រង់ទិសដល់ យុវជន យុវនារីដែលមានបំណងចង់ដឹងនិងឈ្វេងយល់អំពីការត្រាស់ហៅក្នុងជីវិតរបស់ខ្លួន និងរបៀបថ្វាយខ្លួនទៅព្រះជាម្ចាស់។

នៅថ្ងៃបើកកម្មវិធី លោកអភិបាលអូលីវីយេ ក៏បានអប់រំណែនាំដល់យុវជន យុវនារី ចេះរកឃើញវត្តមានព្រះយេស៊ូក្នុងជីវិតរស់នៅប្រចាំថ្ងៃដោយលោកបានលើកឡើងមាគ៌ា៩ចំណុច។

លោកអភិបាលបានមានប្រសាសន៍ថា ៖ «ចំណុចទាំង៩ នេះ ទោះបីជាមិនអាចរកឃើញព្រះយេស៊ូផ្ទាល់នឹងភ្នែក តែវាជាមាគ៌ាមួយឲ្យយើងដឹងថា ជីវិតរបស់យើងភ្ជាប់នឹងវត្តមានរបស់ព្រះជាម្ចាស់ ហើយក្នុងជំនឿរបស់យើង យើងដឹងថាព្រះយេស៊ូមានព្រះជន្មគង់នៅ និងធ្វើដំណើរជាមួយយើងជាប្រចាំថ្ងៃ»។

ក្នុងកម្មវិធីរយៈពេលបីថ្ងៃនេះ យុវជនបានទទួលចំណេះដឹងអប់រំខាងផ្លូវវិញ្ញាណ របៀបអធិដ្ឋានជាក្រុមនិងផ្ទាល់ខ្លួន ស្តាប់ការចែករំលែកបទពិសោធរបស់ក្រុមបព្វជិត-ជិតាអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់៕





# សុភមង្គលគ្រួសារមិនពឹងតែលើទ្រព្យសម្បត្តិ











*អត្ថបទ៖ ម៉េង ភីឡុង*

«សុភមង្គលមិនសំដៅទៅលើទ្រព្យសម្បត្តិ តែសំដៅទៅការរស់នៅជាមួយគ្នាដោយសេចក្តីស្រឡាញ់ ដោយជំនឿ និងអំណរសប្បាយនៅក្នុងចិត្ត។» នេះជាប្រសាសន៍របស់លោក សិលាសួន ហង្សលី អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ថ្លែងទៅកាន់អ្នកចូលរួមក្នុងពិធីបិទឆ្នាំនៃគ្រួសារ។

ឆ្នាំនៃគ្រួសារត្រូវបានប្រារព្ធឡើង អស់រយៈពេលមួយឆ្នាំ ក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ដើម្បីលើកកម្ពស់ជីវិតក្រុមគ្រួសារគ្រីស្តបរិស័ទតាមតំបន់នីមួយៗតាំងពីខែមីនា ឆ្នាំ២០២៣មក ហើយកាលពីថ្ងៃទី៥ ខែធ្នូ នេះ កន្លទៅនេះ។

លោកអភិបាល បានមានប្រសាសន៍ទៀតថា ក្នុងរយៈពេលមួយឆ្នាំនេះ គ្រួសារគ្រីស្តបរិស័ទបានមានឱកាសជួបជុំគ្នាជាលក្ខណៈគ្រួសារ បានចែករំលែកជាមួយគ្នា និងរៀនមេរៀនខ្លះពីលោកបូជាចារ្យ និងដូនជីអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ អំពីអត្ថន័យនៃសេចក្តីស្រឡាញ់ អំពីរបៀបរស់នៅជាគូស្រករ។ លោកបន្តថា «ពេលយើងនិយាយអំពីសេចក្តីស្រឡាញ់គឺមានលក្ខណៈចែករំលែក»។

លោកគង្វាលរូបនេះបន្ថែមថា គ្រួសារជាសហគមន៍តូចមួយដែលយើងត្រូវរស់នៅជាមួយគ្នា បរិភោគជុំគ្នា ធ្វើការជាមួគ្នា ចែករំលែកសេចក្តីស្រឡាញ់ មានទាំងការអធិដ្ឋាន ស្តាប់ព្រះបន្ទូល និងបន្តជំនឿជាមួយគ្នាដែរ នេះបានយើងហៅថា គ្រួសារប្រកបដោយសេចក្តីស្រឡាញ់ ហើយមានសុភមង្គល។

ក្នុងឆ្នាំនៃគ្រួសារនោះ ព្រះសហគមន៍មានរៀបចំជាសិក្ខាសាលាតូចៗតាមតំបន់ ដោយផ្តោតសំខាន់ទៅលើ សារលិខិតរបស់សម្តេចប៉ាបអំពី«អំណរសប្បាយនៃសេចក្តីស្រឡាញ់» វិធីសាស្ត្រកសាងគ្រួសារតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទ្រព្យសម្បត្តិល្អជាងគេរបស់គ្រួសារដែលត្រូវបញ្ជូនបន្តទៅកូនចៅ ការផ្សះផ្សានិងការអត់ទោសជាដើម។

ក្នុងនោះដែរក៏មានបង្ហាញរបាយការណ៍ដែលបានមកពីសក្ខីភាពនៃក្រុមគ្រួសារគ្រីស្តបរិស័ទតាមតំបន់ បានរកឃើញថា មានបញ្ហាមួយចំនួនដូចជាមិនយល់ចិត្តគ្នា គ្មានផែនការគ្រួសារ លំបាកអប់រំកូនព្រោះឪពុកម្តាយមានជំនឿសាសនាផ្សេងពីគ្នា ខ្វះការស្តាប់គ្នាទៅវិញទៅមក សេដ្ឋកិច្ចខ្វះខាត ខ្វះទំនុកចិត្ត ការប្រើប្រាស់គ្រឿងស្រវឹង ខ្វះភាពស្មោះត្រង់ចំពោះគ្នា ។ល។

> គ្រួសារជាសហគមន៍តូចមួយ ដែលយើងត្រូវរស់នៅជាមួយគ្នា បរិភោគជុំគ្នា ធ្វើការជាមួគ្នា ចែករំលែកសេចក្តីស្រឡាញ់ មានទាំងការអធិដ្ឋាន ស្តាប់ព្រះបន្ទូល និងបន្តជំនឿជាមួយគ្នាដែរ នេះបានយើងហៅថា គ្រួសារប្រកបដោយសេចក្តីស្រឡាញ់ ហើយមានសុភមង្គល

ក្នុងបញ្ហាដែលកើតឡើងទាំងនោះក្រុមគ្រួសារទាំងអស់ក៏រកឃើញវិធីសាស្ត្រផ្សេងៗដើម្បីដោះស្រាយរួមមាន ត្រៀមខ្លួននិងឈ្វេងយល់គ្នាឲ្យច្បាស់មុនពេលរៀបការ ទោះបីមានទំនាស់ត្រូវបរិភោគជាមួយគ្នាសម្រុះសម្រួល និងដោះស្រាយបញ្ហារួមគ្នា យោគយល់ឲ្យគ្នាទៅវិញទៅមក ត្រូវមានពេលវេលានៅជាមួយគ្នា សម្រុះសម្រួលគ្នាមុនពេលចូលដំណេក ត្រូវពិភាក្សាគ្នាអំពីការអប់រំកូន។ល។

ជាមួយគ្នានេះដែរលោកអភិបាលព្រះសហគមន៍បានបញ្ជាក់ថា ការបិទឆ្នាំនៃគ្រួសារមិនមែនបិទសកម្មភាពនោះទេ។ លោកបានលើកទឹកចិត្តដល់លោកបូជាចារ្យ ដូនជី និងអ្នកណែនាំព្រះសហគមន៍ក្នុងភូមិភាគឲ្យបន្តយកចិត្តទុកដាក់ដល់ក្រុមគ្រួសារ ដោយជួយលើកទឹកចិត្តគ្នា ជាពិសេសគ្រួសារវ័យក្មេងឲ្យយល់ពីជីវិតរស់នៅជាគ្រួសារ។ ត្រូវបង្កើតកម្មវិធីណែនាំអប់រំដល់យុវជន អំពីការជ្រើសរើសគូស្រករ។ លោកថា បើក្នុងគ្រួសារមានបញ្ហាពិបាកដោះស្រាយ សូមអធិដ្ឋានជាមួយព្រះជាម្ចាស់ ឬទៅជួបចាស់ទុំលោកបូជាចារ្យឲ្យជួយណែនាំ។

អ្នកស្រី ផ្សេងក្លែល មកពីព្រះសហគមន៍កាតូលិក សន្តយ៉ាកុប ដាក់ដាំបានឲ្យដឹងថា ការណែនាំរបស់ព្រះសហគមន៍គឺសំខាន់ ហើយព្រះសហគមន៍នាំឲ្យយើងរិះគិតធ្វើជីវិតជាគ្រួសារក្នុងព្រះសហគមន៍ ឲ្យយើងទទួលខុសត្រូវធ្វើយ៉ាងដូចម្តេចដើម្បីជាគំរូដល់អ្នកដទៃ ធ្វើជាគំរូដល់កូនៗ ដោយបង្ហាញក្តីស្រឡាញ់។

លោកបូជាចារ្យ ស្នេផាន សៃសាត ទទួលខុសត្រូវព្រះសហគមន៍៤ក្នុងតំបន់កំពង់ចាមបានឲ្យដឹងថា ជីវិតក្រុមគ្រួសារគឺជួបប្រឈមនឹងបញ្ហាជាច្រើន ហើយក្នុងនាមលោកជាអ្នកណែនាំព្រះសហគមន៍នឹងបន្តយកចិត្តទុកដាក់ជួយដល់ក្រុមគ្រួសារ បន្តសួរសុខទុក្ខ បន្តអធិដ្ឋានតាមក្រុមគ្រួសារ បង្កើតសិក្ខាសាលាអំពីគ្រួសារ ដើម្បីជួយឲ្យក្រុមគ្រួសាររស់នៅប្រកបដោយសុភមង្គល។

លោកបន្តទៀតថា គ្រួសារជាសង្គមតូចមួយ ហើយសេចក្តីស្រឡាញ់គឺផ្តើមចេញពីក្រុមគ្រួសារ កិច្ចការប្រកាសដំណឹងល្អក៏ចេញពីក្រុមគ្រួសារ។ ពិធីបុណ្យ ការអធិដ្ឋាន ការបន្តជំនឿក៏ចេញពីក្រុមគ្រួសារ។ លោកបន្ថែមថា គ្រួសារជាគ្រឹះមួយសំខាន់មុននឹងចូលទៅក្នុងក្រុមគ្រួសារ

# មណ្ឌលសុខភាពថែរក្សាអ្នកជំងឺ ផ្នែកសរសៃ ព្យាបាលដោយឥតគិតថ្លៃ











*អត្ថបទ៖ កែវ កញ្ញា*

បន្ទប់ធំមួយដែលមានឧបករណ៍ធ្វើចលនាជាច្រើន និងមានគ្រែប្រមាណជាង១០តម្រៀបជាជួរ មានអ្នកខ្លះសម្រាកលើនោះ ដោយទឹកមុខស្រងូត និងគ្នួញត្អែរពីស្ថានភាពរាងកាយ និងការឈឺចាប់របស់ខ្លួនជូនដល់ស្ត្រីម្នាក់ជាអ្នកមើលការខុសត្រូវនៅទៅនោះ ដែលកំពុងទទួលគាត់ដោយរាក់ទាក់និងទន់ភ្លន់។

«ឈឺ នៅឈឺនៅឡើយ តែមិនដូចពេលមុនទេ» អ្នកស្រី អ៊ឹម ឆេងលីម អាយុ៥៣ឆ្នាំ រស់នៅក្នុងភូមិរតនៈ ឃុំស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ជាពុទ្ធបរិស័ទបានបន្លឺសំឡេងឡើងទាំងរដាក់រដុបប្រាប់ម្ចាស់កន្លែង។

គាត់បានមកកន្លែងនេះ ដើម្បីទទួលសេវាព្យាបាលដោយចលនា។ ឆេងលីម ឲ្យដឹងថា គាត់មានជំងឺស្លាប់មួយចំហៀងខ្លួន និយាយមិនច្បាស់ទេព្រោះមាត់វៀច។ គាត់ឲ្យដឹងថា «មកពីលើសឈាមហើយដួលបានបណ្តាលឱ្យស្លាប់មួយចំហៀងខ្លួន»។

អ្នកជំងឺរូបនេះ បានមកព្យាបាលនៅមណ្ឌលសុខភាពថែរក្សាអ្នកជំងឺខាងសរសៃដែលជាកម្មវិធីសុខភាពរបស់ព្រះសហគមន៍កាតូលិក ស្ថិតនៅក្នុងបរិវេនព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ(ពេទ្យឃាជី)ក្នុងក្រុងបាត់ដំបង ដែលស្ថិតនៅភាគខាងលិចនៃប្រទេសកម្ពុជា។

រយៈពេល២សប្តាហ៍ដែលគាត់បានទទួលការព្យាបាល គាត់អាចដើរបានឡើងវិញខ្លះៗ។ ដៃក្បាលនិងខ្លួនភ្ជាប់ទៅដោយខ្សែអគ្គិសនីរួមនិងម្ទុវិទ្យាសាស្ត្រដោតពេញមួយចំហៀងខ្លួនផង ស្ត្រីរូបនេះបន្តថា «មុន ឡើងជណ្តើរមិនរួចទេ ឥលូវដើរបានតិចៗហើយ។ សម្រាប់ទទួលការព្យាបាល២អាទិត្យហ្នឹងដើរបានច្រើន»។

ឆេងលីម ដែលកំពុងសម្រាកព្យាបាល បានបន្តទៀតថា គាត់គ្មានលទ្ធភាពទៅពេទ្យឈ្នួល ហើយទៅពេទ្យរដ្ឋក៏អត់មានលទ្ធភាពដែរ «ខ្ញុំមកព្យាបាលនៅទីនេះ អត់អស់លុយហើយជា និងម៉្យាងទៀតទៅពេទ្យធំ(ពេទ្យរដ្ឋ)ត្រូវចាំយូរទៀត»។

អ្នកស្រីបានលើកសរសើរពីសេវាកម្មនៅទីនេះថា «ល្អទាំងពេទ្យ ល្អទាំងកន្លែង ហើយមានកន្លែងហាត់ប្រាណ បើនៅផ្ទះអត់មានអ្វីហាត់ប្រាណបណ្តាលឱ្យខ្ជិល ហើយខ្ញុំមកជារៀងរាល់ថ្ងៃ មួយថ្ងៃម្តងដោយចំណាយមួយព្រឹកធំ ប៉ុន្តែដើម្បីសុខភាព ដើម្បីឆាប់ជាគឺត្រូវតែមក»។

ក្នុងសម្លៀកបំពាក់អាវបំពង់ធំវែងពណ៌ផ្ទៃមេឃដែលជាឯសណ្ឋានដូនជី ម៉ារី ចន្ទ ជាអ្នកទទួលខុសត្រូវមណ្ឌលសុខភាពថែរក្សាអ្នកជំងឺខាងសរសៃ មានប្រសាសន៍ថា សព្វថ្ងៃយើងទទួលអ្នកជំងឺភាគច្រើនងាប់មួយចំហៀងខ្លួន។ គាត់ប្រាប់ទៀតថា កាលពីមុន មនុស្សវ័យ៥០ឡើង ទើបមានជំងឺនោះ តែសព្វថ្ងៃនេះវ័យក្មេងក៏មានដែរ ដោយសារលើសសម្ពាធឈាម ឬដោយសារគ្រោះថ្នាក់។

ដូនជីបន្តថា កម្មវិធីនេះក៏ទទួលព្យាបាលទាក់ទងខាងសរសៃ ឈឺស្មា គ្រេចចង្កេះ ដែលកើតឡើងដោយសារលើករបស់ធ្ងន់ដែរគឺព្យាបាលដោយធ្វើចលនានិងខ្លះដោយម៉ាស្សាចាប់សសៃ។

កន្លែងព្យាបាលនេះ ចាប់បើកទទួលអ្នកជំងឺពីម៉ោងប្រាំបីព្រឹកដល់ម៉ោងដប់មួយកន្លះព្រឹក ហើយនៅពេលរសៀលក្រុមបុគ្គលិកធ្វើដំណើរទៅផ្ទះអ្នកជំងឺតាមភូមិ។ ដូនជីចន្ទ បញ្ជាក់ថា «ដោយសារភាគច្រើនមានអ្នកខ្លះនៅតាមភូមិគាត់ក្រ គាត់អត់មានម៉ូតូជិះមកកន្លែងយើង យើងចុះតាមភូមិដើម្បីជួយគេហើយមើលស្ថានភាពរបស់គេ»។

សេវកម្មផ្នែកសសៃនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩ នៅឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង ប៉ុន្តែបានផ្លាស់មកទីតាំងបច្ចុប្បន្ននេះក្នុងឆ្នាំ២០១៤ ដើម្បីទទួលអ្នកជំងឺបានច្រើនជាងមុន។អ្នកមកទទួលសេវាកម្មនៅទីនេះមិនតម្រូវឲ្យបង់ប្រាក់កំណត់ទេ តែអាចបង់ជាវិភាគទានតាមលទ្ធភាពដែលអាចធ្វើទៅបាន។

ដូនជីទទួលខុសត្រូវ ឲ្យដឹងថា អ្នកងាប់មួយចំហៀងគេអត់ធ្វើការអីបាន គេអត់បានលុយ ហើយត្រូវមានម្នាក់ជួយថែមទៀត អីចឹងយើងអត់យកលុយគាត់ទេ។ យើងដាក់ធុងវិភាគទាននៅខាងមុខ អ្នកណាចង់ដាក់ប៉ុន្មានតាមចិត្ត គេមានចិត្តទូលាយគេដាក់ អត់ដាក់ក៏អត់អីដែរ។

មុនកូវីដ-១៩រាតត្បាត មានអ្នកជំងឺពីខេត្តនានាដូចជាបន្ទាយមានជ័យសៀមរាបពោធិ៍សាត់ ប៉ៃលិន ភ្នំពេញនិងបាត់ដំបងជាដើម បានមករកសេវាព្យាបាល ហើយនៅមណ្ឌលនេះបានផ្តល់នូវបន្ទប់សម្រាក និងផ្តល់ម្ហូបអាហារដល់ពួកគាត់។

ដូនជីចន្ទបានឲ្យដឹងទៀតថា គោលដៅសំខាន់សម្រាប់មណ្ឌលមួយនេះ គឺជួយគាំពារ និងព្យាបាលសុខភាពរបស់ប្រជាជនក្រីក្រដែលគ្មានលទ្ធភាពព្យាបាលនៅតាមមន្ទីរពេទ្យនានា។ គាត់បន្ថែមថា អ្នកមានគេទៅថៃ គេទៅវៀតណាម តែអ្នកក្រគ្មានកន្លែងទៅទេ ព្រោះការព្យាបាលរបៀបនេះអស់លុយច្រើន។កន្លែងយើង ស្វាគមន៍គ្រប់មនុស្ស។មួយរយៈមុនលោកសង្ឃមកច្រើន ហើយដូនជីក៏ច្រើនដែរ។ ដូនជីបញ្ជាក់ «យើងអត់គិតថ្លៃសេវា ហើយក៏អត់គិតសាសនាដែរ»។

ក្នុងមណ្ឌលសុខភាពថែរក្សាអ្នកជំងឺខាងសរសៃ មានបុគ្គលិកចំនួន៦នាក់ ដែលជាគ្រីស្តបរិស័ទកាតូលិក។ ដូនជីរូបនេះបន្ថែមថា កិច្ចការដែលពួកគាត់កំពុងធ្វើនេះ គឺធ្វើជំនួសព្រះយេស៊ូ បន្តការងាររបស់ព្រះអង្គ «យើងស្រឡាញ់ព្រះអង្គ យើងស្រឡាញ់អ្នកជំងឺ»។

កំពុងម៉ាស្សាចាប់សសៃឲ្យយុវជនម្នាក់លោក ហេង វុទ្ធីណា ជាបុគ្គលិកម្នាក់ធ្វើការនៅទីនេះជិត៦ឆ្នាំហើយ និយាយថា គាត់សប្បាយចិត្តនៅពេលបានឃើញស្នាមញញឹមរបស់អ្នកជំងឺទាំងអស់។ គាត់បានចាប់អារម្មណ៍កិច្ចការងារនេះខណៈពេលជូនអ្នកជំងឺម្នាក់មកទទួលការព្យាបាល។

ទោះបីជាវុទ្ធីណា មិនមានជំនាញនេះពីមុនមក តែគាត់បានហ្វឹកហាត់ខ្លួន ដើម្បីបម្រើនិងព្យាបាលអ្នកជំងឺ។ គាត់ពោលថា «យើងជាឧបករណ៍របស់ព្រះអង្គ [...]យើងជឿថានេះការងារព្រះអង្គ ព្រះអង្គនឹងបង្ហាញការអស្ចារ្យឱ្យពួកគាត់អាចល្អប្រសើរតាមរយៈយើង»។





# ដូនជី អេង សានី៖ «ព្រះសហគមន៍គឺជាគ្រួសាររបស់ខ្ញុំ»



*អត្ថបទ៖ ចាន់ ម៉ានុត*

ក្នុងសម្លៀកបំពាក់សាមញ្ញធម្មតា តែមានពាក់ខ្សែកឈើឆ្កាងឈើមួយតំណាងជាបព្វជិតា ម៉ារី តេរេស អេងសានី ឲ្យដឹងថា គាត់បានចាប់អារម្មណ៍អំពីការរួបរួមរបស់គ្រីស្តបរិស័ទ ទោះបីជាមិនដែលស្គាល់គ្នា មិនសូវមានជីវភាពធូរធារ ប៉ុន្តែការចូលរួមអធិដ្ឋាន ការចូលរួមចែករំលែកជាមួយបងប្អូនឯទៀតៗ ការសួរសុខទុក្ខអ្នកជំងឺ អ្នកជាប់នៅមន្ទីរឃុំឃាំង បានជំរុញឲ្យយុវតីរូបនេះផ្លាស់ប្តូរជំនឿព្រោះវាត្រូវជាមួយនឹងអត្តចរិករបស់គាត់។

បច្ចុប្បន្នដូនជីរូបនេះ កំពុងបម្រើការងារនៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន។ គាត់ជាអ្នកណែនាំនិងរៀបចំកម្មវិធីមួយចំនួនដូចជា អប់រំជំនឿ បង្ហាត់ចម្រៀងដល់យុវជន រៀបចំពិធីបុណ្យ និងទំនាក់ទំនងជាមួយគណៈកម្មការក្នុងព្រះសហគមន៍ និងជាអ្នកសម្របសម្រួលមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិក។

អតីតកាលជាយុវនារីពុទ្ធបរិស័ទម្នាក់ ក្នុងគ្រួសារដែលត្រូវការជំនួយ ក្នុងឆ្នាំ២០០២ សានីបានចូលរៀនវិជ្ជាជីវៈកាត់ដេរនៅក្នុងមណ្ឌលរបស់ព្រះសហគមន៍កាតូលិកនៅខេត្តស្វាយរៀង ដែលនៅទីនោះហើយ គាត់បានស្វែងរកអត្ថន័យជីវិតជាគ្រីស្តបរិស័ទ ដោយចូលរួមកម្មវិធីអប់រំជំនឿជារៀងរាល់ថ្ងៃអាទិត្យ។

យុវនារីរូបនេះ បន្ថែមថា ការអប់រំទូន្មាននិងការអនុវត្តអំពើល្អក្នុងជីវិតប្រចាំថ្ងៃ ធ្វើឱ្យគាត់មានចិត្តស្រលាញ់ចំពោះអ្នកឯទៀតៗកាន់តែខ្លាំងឡើង ហើយបន្តិចម្តងៗ ព្រះយេស៊ូធ្វើឱ្យគាត់យល់ច្បាស់ពី«ធម៌មេត្តាករុណា គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់»។

ដូនជី អេង សានី កើតនៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៨១ ជាកូនស្រីទី៣ក្នុងក្រុមគ្រួសារពុទ្ធបរិស័ទកសិករ ស្ថិតនៅភូមិថ្កូវ ឃុំកំពង់ប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានកូនចំនួន៤នាក់ ស្រី២ និងប្រុស២។

ស្ត្រីរូបនេះ បានសម្រេចចិត្តទទួលជីវិតថ្មីជាគ្រីស្តបរិស័ទ ដោយទទួលអគ្គសញ្ញាជ្រមុជទឹកនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០៦ ចំថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។

ការផ្លាស់ប្តូជំនឿសាសនានៅតាមទីជនបទមិនសូវមានអ្នកគាំទ្រនោះទេ ព្រោះប្រជាជនតែងយល់ថា គ្រីស្តសាសនាជាសាសនារបស់ជនបរទេសប៉ុណ្ណោះ។

> ព្រះជាម្ចាស់ពិតជាចង់ឱ្យរិះគិតអំពីជីវិតអ្នកបួស សូមកុំខ្លាច កុំខ្លាចនឹងឈានជើងចូលដើម្បីឈ្វេងយល់។ ហើយបន្តិចម្តងៗ យើងនឹងស្គាល់ យើងស្រលាញ់ យើងនឹងស្ម័គ្រចិត្តថ្វាយខ្លួនអស់មួយជីវិត។

«គេ(អ្នកភូមិ)ថាហេតុអីបានជាខ្ញុំទៅជឿលើសាសនាបរទេស សាសនាដែលមិនឱ្យគោរពឪពុកម្តាយ» សានីបញ្ជាក់។

ទោះបីជាយ៉ាងនេះក្តី សានីនៅតែមានកម្លាំងចិត្តដើរតាមជំនឿនេះទៅមុខទៀត ដោយសារគ្រួសារបានគាំទ្រដល់គាត់ ហើយណែនាំដល់អ្នកជិតខាង បើទោះជាគាត់មិនបានស្គាល់គ្រីស្តសាសនាច្រើនប៉ុណ្ណាក៏ដោយ។

សានីឲ្យដឹងថា ក្រុមគ្រសាររបស់ខ្ញុំមិននិយាយអ្វីឱ្យប៉ះពាល់ផ្លូវចិត្តនោះទេ មានតែលើកទឹកចិត្តខ្ញុំរហូតថាកុំខ្វល់នឹងពាក្យសម្តីរបស់ពួកគេ គេមិនបានមកចិញ្ចឹមយើងទេ អ្វីដែលកូនគិតថាល្អ សូមបន្តធ្វើវាចុះ។

ក្រោយពីក្លាយជាគ្រីស្តបរិស័ទ បាន២ឆ្នាំ ក្នុងវ័យ២៧ឆ្នាំ យុវតីរូបនេះ បានឈានមួយជំហានទៀត រិះគិតទៅកាន់ជីវិតជាអ្នកបួស ព្រោះមានគំរូជាច្រើនដែលគាត់បានឃើញពីលោកបូជាចារ្យបងប្រុស និងដូនជី ជាជនបរទេស ជាពិសេសគឺការលះបង់ពេលវេលា លះបង់ប្រទេសជាតិ លះបង់ក្រុមគ្រួសារមកបម្រើកិច្ចការនៅប្រទេសកម្ពុជា។

«តើមានកម្លាំងអ្វីជំរុញឲ្យពួកគាត់ធ្វើបែបនេះ?» ហើយគាត់តែងសួរខ្លួនឯងថា «តើក្នុងនាមជាកូនខ្មែរមួយរូបអាចធ្វើបែបនេះបានដែរឬអត់?»

ក្នុងឆ្នាំ២០០៨ គាត់បានឈានជើងចូលក្រុមអ្នកបួស ក្នុងក្រុមគ្រួសារបងស្រីឧបការគុណនៅព័រស៊ី ក្នុងទីក្រុងភ្នំពេញ។ ទោះជាមានការរិះគន់យ៉ាងណាពីសំណាក់ប្រជាជនពុទ្ធបរិស័ទនិងមិត្តភក្តិមួយចំនួន ព្រោះពួកគាត់គិតថា សានីប្រហែលមានបញ្ហាផ្លូវចិត្តអ្វីមួយទើបណែនាំឲ្យទៅបួស ប៉ុន្តែដោយការគាំទ្រពីសំណាក់សមាជិកក្រុមគ្រួសារ គាត់ទទួលបានអំណរសប្បាយក្នុងជីវិតជាអ្នកបួស។

«មានពេលខ្លះគេសួរខ្ញុំថា ហេតុអ្វីបានជាចូលបួសក្រុមនេះ ឃើញមានបងស្រីភាគច្រើនជាជនជាតិវៀតណាម? ហេតុអ្វីបានជាមិនទៅបួសក្រុមផ្សេងបានទៅនៅបរទេស» ដូនជីខ្មែររូបនេះ បន្តថា សម្រាប់គាត់ បំបួសគឺជាការប្រកាសដំណឹងល្អ មិនថានៅកន្លែងណាឬជាតិសាសន៍ណានោះទេ «ខ្ញុំស្ម័គ្រចិត្តបម្រើព្រះយេស៊ូ ដូច្នេះសេចក្តីស្រលាញ់របស់ព្រះអង្គគ្មានព្រំដែនឡើយ»។

អង្គុយបណ្តើរជជែកបណ្តើរ អំពីជីវិតជាអ្នកបួស ដូនជីសម្បុរសណ្តែកបាយ មានមាឌតូចខ្ពស់ បានបន្លឺទៀតថា បេសកកម្មរបស់ក្រុមបងស្រីឧបការគុណ មានលក្ខណៈពិសេសម្យ៉ាងគឺរបៀបបម្រើបងប្អូនតាមជនបទ តាមស្ថានភាពជាក់ស្តែង និងតម្រូវការរបស់ព្រះសហគមន៍ «ហើយម្យ៉ាងទៀតខ្ញុំស្រលាញ់ការបម្រើព្រះសហគមន៍ បើទោះបីជាព្រះសហគមន៍ធំឬតូច ព្រះសហគមន៍គឺជាគ្រួសាររបស់ខ្ញុំ»។

ដូនជី ម៉ារី តេរេស អេង សានី បានថ្វាយពាក្យសច្ចាលើកដំបូងនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១១។ ហើយបានបន្តការសិក្សានៅប្រទេសបារាំងរយៈពេល៣ឆ្នាំនិងបានថ្វាយពាក្យសច្ចាជានិរន្តន៍នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២។

ដំណើរជាអ្នកបួសមិនមែនស្រួលទាំងអស់នោះទេ ដូនជីសានីក៏ធ្លាប់ជួបបញ្ហាផ្សេងៗ រួមមាន បាក់ទឹកចិត្ត ពិបាកចិត្ត និងទំនាស់ពាក្យសម្តីជាដើម ប៉ុន្តែ ដោយមានក្តីស្រឡាញ់ និងអធិដ្ឋានក្នុងភាពស្ងៀមស្ងាត់ ឬរកលោកបូជាចារ្យម្នាក់ដើម្បីចែករំលែកនិងផ្តល់យោបល់បានជួយឱ្យអារម្មណ៍ផ្លូវវិញ្ញាណរឹងមាំឡើងវិញ។

និយាយដោយភាពជឿជាក់ និងឆ្លងតាមពិសោធន៍ដែលមានកន្លងមក និងក្នុងនាម ជាលេខានិងជាទីប្រឹក្សាប្រធានខេត្តនៃក្រុមបងស្រីឧបការគុណនៅប្រទេសកម្ពុជា ដូនជីរូបនេះ បានផ្តាំផ្ញើដល់យុវជនយ៉ាងនេះថា ការត្រាស់ហៅរបស់ព្រះជាម្ចាស់មានពេលខ្លះយើងអត់ច្បាស់ ប៉ុន្តែសំខាន់ពេលដែលយើងឮថា ព្រះជាម្ចាស់ពិតជាចង់ឱ្យរិះគិតអំពីជីវិតអ្នកបួស សូមកុំខ្លាច កុំខ្លាចនឹងឈានជើងចូលដើម្បីឈ្វេងយល់។ ហើយបន្តិចម្តងៗ «យើងនឹងស្គាល់ យើងស្រលាញ់ យើងនឹងស្ម័គ្រចិត្តថ្វាយខ្លួនអស់មួយជីវិត»។

ក្តីបំណងរបស់ដូនជីរូបនេះ គឺធ្វើការជាមួយយុវជន យុវនារី ដើម្បីចែករំលែកជាមួយពួកគេ និងរៀនពីពួកគេ ដើម្បីអភិវឌ្ឍន៍ចំណេះដឹងក្នុងការបម្រើព្រះសហគមន៍។ គាត់បានឲ្យដឹងទៀតថា «ខ្ញុំចង់ឱ្យប្រទេសកម្ពុជាយើងមានលោកបូជាចារ្យ បព្វជិត-ជិតាខ្មែរឱ្យបានច្រើន ដើម្បីបម្រើព្រះសហគមន៍នឹងជួយដល់សង្គមក្នុងការអប់រំនិងកសាងសន្តិភាពរវាងគ្នានិងគ្នា»។







# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម



## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង



## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

